# ព្រឹទ្ធសភា

# *SENATE MAGAZINE*

## ទស្សនាវដ្ដីប្រចាំខែវិច្ឆិកា




លេខ ២៦៥ ឆ្នាំទី២២
ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២២

Issue 265 Volume 22
Before Christ 2566 Common Era 2022

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចូលរួមទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតកងយោធពលខេមរភូមិន្ទខួបលើកទី៦៩ ....................................... ១
- សម្តេចប្រធានព្រឹទ្ធសភាអញ្ជើញថ្លែងសុន្ទរកថាក្នុងពិធីបើកមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ....................................................................... ២
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបនាយករដ្ឋមន្ត្រីវៀតណាម ..............................................................៥
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបជាមួយឯកឧត្តមអនុប្រធានាធិបតីឥណ្ឌា.......................................................៨
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្តមប្រធានរដ្ឋសភាវៀតណាម.............................................................. ១១
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបប្រធានរដ្ឋសភាម៉ារ៉ុក .................................................................. ១៤
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបពិភាក្សាការងារជាមួយលោកជំទាវប្រធានរដ្ឋសភាអាស៊ែបៃហ្សង់ .................. ១៦
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបសវនាការជាមួយប្រធានរដ្ឋសភាឡាវ ......................................................... ១៩
- សម្តេចប្រធានព្រឹទ្ធសភាដឹកនាំគណៈប្រតិភូជាន់ខ្ពស់ទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសវៀតណាម.............២២
- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភាជួបពិភាក្សាការងារទ្វេភាគីជាមួយអនុប្រធានក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី.................................................................................................២៥
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ......................................................... ២៧


## សកម្មភាពគណៈកម្មការ




- គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយក្រសួងព័ត៌មាន..................២៩
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ចុះសួរសុខទុក្ខ និងនាំយកអំណោយជូនប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន២៣៤គ្រួសារ នៅស្រុកត្បូងឃ្មុំ......... ៣០
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ....................................... ៣១
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ............................................................. ៣២
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨.................................................. ៣៣
- ការងារទទួលពាក្យបណ្តឹង.................................................................................................................៤២
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........................................................................... ៤៣


## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងកំណត់ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២២.................................................៤៨
- ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញធ្វើបាឋកថាស្តីពី តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភាកម្ពុជា ជូនសិស្សមន្ត្រីជាន់ខ្ពស់ និងកម្មសិក្សាការី នៃសាលាភូមិន្ទរដ្ឋបាល ......................៤៩
- សិក្ខាសាលាស្តីពី “សហគមន៍ជោគវាសនារួមកម្ពុជាចិន ប្រកៀកស្មាគ្នាឆ្ពោះទៅមុខក្នុងដំណើរថ្មី” ប្រព្រឹត្តទៅនៅព្រឹទ្ធសភាកម្ពុជា........................................................................................៥០
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ..................................................៥២



**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម អ៊ុំ សារឹទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម លីម ប៊ុនហុក
ឯកឧត្តម កែវ ចាន់ណា
ឯកឧត្តម សុខ រិទ្ធី
ឯកឧត្តម ជួន ណា
ឯកឧត្តម គឹម ពិសិដ្ឋ
លោក ជួន សុខធី
លោក ទេព មករា
លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
លោកស្រី សុខ សុជាតា


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់កម្ពុជា និងប្រធានសភាបណ្តាប្រទេសសមាជិក AIPA។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាឡាវ។*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**
**E-mail : oumsarith.sgsenate@gmail.com**
**Website: www.senate.gov.kh**
**www.elibrary.senate.gov.kh**
**Facebook: www.facebook.com/senateofcambodia**

# ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចូលរួមទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតកងយោធពលខេមរភូមិន្ទខួបលើកទី៦៩



*ទិដ្ឋភាពក្នុងព្រះរាជពិធីបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា*

សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ឯកឧត្ដមកិត្ដិនីតិកោសលបណ្ឌិត **ស៊ុំ ភា** អនុប្រធានទី១ ឯកឧត្ដមកិត្ដិសង្គហបណ្ឌិត **ទេព ខន** អនុប្រធានទី២ ព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ នាព្រឹកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២២ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតកងយោធពលខេមរភូមិន្ទខួបលើកទី៦៩ នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២ នៅបរិវេណវិមានឯករាជ្យ រាជធានីភ្នំពេញ។

ព្រះរាជពិធីនេះ ប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដោយមានព្រះរាជវត្តមាន សម្ដេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ និងវត្តមានឥស្សរជនជាន់ខ្ពស់ នៃព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល អង្គទូត និងតំណាងស្ថានទូតនៃបណ្ដាប្រទេសជាមិត្តប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ព្រះរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី អ្នកមុខអ្នកការ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន និងប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សយ៉ាងច្រើនកុះករ។

ទិវាបុណ្យឯករាជ្យជាតិ ថ្ងៃទី៩ វិច្ឆិកា ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ ដើម្បីឧទ្ទិសដល់ព្រះរាជបូជនីយកិច្ចរបស់អតីតព្រះមហាក្សត្រ ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** "ព្រះបរមរតនកោដ្ឋ" ដែលព្រះអង្គបានលះបង់ព្រះកាយពល និងព្រះបញ្ញាញាណយ៉ាងក្លៀវក្លាបំផុត ដើម្បីតស៊ូក្នុងក្របខ័ណ្ឌ នៃព្រះរាជបូជនីយកិច្ច ទាមទារឯករាជ្យពីអាណានិគមបារាំង។ តាមប្រវត្តិសាស្ត្រ បារាំងបានដាក់អាណានិគមត្រួតត្រាលើប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៨៦៣ រហូតដល់ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ទើបប្រទេសបារាំងបានប្រកាសប្រគល់ឯករាជ្យពេញលេញដល់កម្ពុជាវិញ។

ប្រទេសកម្ពុជាក្រោយពីទទួលបានឯករាជ្យ ដោយមានព្រះករុណា**ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គឺជាព្រះអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមបានដឹកនាំកម្ពុជា ប្រកបដោយសុខសន្តិភាព និងវឌ្ឍនភាពលើគ្រប់វិស័យ។ កូនចៅប្រជានុរាស្ត្រកម្ពុជាគ្រប់ៗរូបសូមចងចាំ និងដឹងនូវព្រះគុណូបការៈដ៏ធំធេង នៃព្រះករុណា **ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ចំពោះប្រជាជាតិ និងប្រជារាស្ត្រកម្ពុជា៕

(អត្ថបទ៖ ទេព មករា រូបភាព៖ អ៊ុក ប៉ូលីន)





*ទិដ្ឋភាពក្នុងព្រះរាជពិធីបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា*

# សម្តេចប្រធានព្រឹទ្ធសភាអញ្ជើញថ្លែងសុន្ទរកថាក្នុងពិធីបើក មហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញចូលរួមជាគណៈអធិបតីក្នុងAIPA-43*

នាព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីបើកមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (ASEAN Inter-Parliamentary Assembly (AIPA-43) ក្រោមមូលបទ "បោះជំហានជាមួយគ្នា ដើម្បីចីរភាព បរិយាបន្ន និងភាពធន់របស់អាស៊ាន" នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ។

ពិធីបើកមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ប្រព្រឹត្តទៅដោយមានការចាក់បញ្ចាំងវីដេអូព្រះរាជសាររបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សុន្ទរកថាស្វាគមន៍របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា សុន្ទរកថាគន្លឹះរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសុន្ទរកថាបើកមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ដោយសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភាបណ្តាប្រទេសសមាជិកអាយប៉ា និងគណៈប្រតិភូ ភ្ញៀវកិត្តិយស ព្រមទាំងអ្នកសង្កេតការណ៍។

ថ្លែងសុន្ទរកថាស្វាគមន៍នាឱកាសនោះ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា ក្នុងនាមសភាកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះគណៈប្រតិភូទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងពិធីបើកមហាសន្និបាតអាយប៉ាលើកទី៤៣។ ដោយសារតែស្ថានភាព នៃការរីករាលដាលជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្នបានធូរស្បើយ និងស្ថិតនៅក្រោមស្ថានភាពអាចគ្រប់គ្រងបាន ទើបអនុគ្រោះឱ្យសភាកម្ពុជាអាចធ្វើជា






*សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញថ្លែងសុន្ទរកថាស្វាគមន៍ក្នុងAIPA-43*

ម្ចាស់ផ្ទះរៀបចំមហាសន្និបាតអាយប៉ាដោយផ្ទាល់យ៉ាងអធិកអធម និងមានសុវត្ថិភាពក្នុងឆ្នាំនេះ បន្ទាប់ពីត្រូវបានរៀបចំតាមប្រព័ន្ធនិម្មិត២ដងរួចមកហើយ។

ឆ្លៀតក្នុងឱកាសនោះ សម្ដេចបានសម្ដែងនូវការអបអរសាទរចំពោះសភា នៃប្រទេសប្រ៊ុយណេដារូសាឡឹម ដែលបានធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និបាតអាយប៉ាលើកទី៤២ប្រកបដោយជោគជ័យ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា មហាសន្និបាតអាយប៉ាលើកទី៤៣ក្នុងឆ្នាំនេះ ពិតជាមានលក្ខណៈពិសេសដោយហេតុថាឆ្នាំនេះគឺជាខួបអនុស្សាវរីយ៍លើកទី៤៥ នៃការបង្កើតមហាសន្និបាតអាយប៉ាផង និងជាខួបលើកទី៥៥នៃការបង្កើតអាស៊ានផង។ ព្រឹត្តិការណ៍ទាំងបីនេះ គឺពិតជាព្រឹត្តិការណ៍ដ៏សំខាន់ក្នុងប្រវត្តិសាស្ត្រ នៃដំណើរដ៏វែងឆ្ងាយរបស់អាស៊ានក្នុងការកសាងសហគមន៍អាស៊ាន ដែលកន្លងមកបានយកឈ្នះរាល់បញ្ហាប្រឈម និងវិបត្តិ។ តាមរយៈស្មារតីសាមគ្គីភាព និងឯកភាពដ៏អស្ចារ្យ នាំឱ្យអាស៊ានបានកសាងខ្លួនរឹងមាំជាងពេលណាៗទាំងអស់។ ក្នុងរយៈពេល៤៥ឆ្នាំ ចាប់តាំងពីអាយប៉ាត្រូវបានបង្កើត អាយប៉ាបានវិវឌ្ឍខ្លួនទៅជាអង្គការអន្តរសភាតំបន់ដ៏រឹងមាំ ដោយបានខិតខំព្យាយាមយ៉ាងសកម្ម និងប្រកបដោយប្រសិទ្ធភាពរហូតនូវគោលដៅដ៏ថ្លៃថ្លាក្នុងការលើកកម្ពស់សាមគ្គីភាព ការយោគយល់គ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ មិនត្រឹមតែក្នុងចំណោមសភាជាសមាជិកអាយប៉ាប៉ុណ្ណោះទេ ប៉ុន្តែជាមួយនឹងសភាសង្កេតការណ៍ និងដៃគូស្ថាប័នផ្សេងទៀត។ អាយប៉ាបានបង្ហាញឱ្យឃើញនូវតួនាទីស្នូលរបស់ខ្លួនក្នុងនាមជាស្ថាប័ននីតិប្បញ្ញត្តិ ដែលជាផ្នែកសំខាន់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាច្រើនទិដ្ឋភាព និងជាចំណែកចូលរួមដែលមិនអាចខ្វះបានក្នុងការកសាងសហគមន៍អាស៊ាន។ បន្ថែមពីលើនេះ អាយប៉ាបានដើរតួនាទីជាវេទិកាអន្តរសភាដ៏សំខាន់ក្នុងការលើកកម្ពស់តួនាទីរបស់សមាជិកសភា ដើម្បីតំណាងឱ្យសំឡេងរួមរបស់ប្រជាជនអាស៊ាន។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់បន្ថែមថា ចាប់តាំងពីចូលជាសមាជិកអាយប៉ាក្នុងឆ្នាំ១៩៩៩មក សភាកម្ពុជាពិតជាមានមោទនភាពដែលបានចូលរួមចំណែកជាផ្នែកមួយនៃអាយប៉ា បានធ្វើដំណើរជាមួយនឹងអាយប៉ាលើផ្លូវដ៏ឆ្ងាយកន្លងមក ព្រមទាំងបានប្ដេជ្ញាចិត្តនឹងបន្តដំណើរជាមួយអាយប៉ា ដើម្បីកសាងសន្តិភាព និងវិបុលភាពដល់សហគមន៍អាស៊ានទាំងមូល។ នៅពេលដែលយើងសម្លឹងឆ្ពោះទៅអនាគតរួមគ្នា គឺច្បាស់ណាស់ថា វៀរលែងតែយើងមានឆន្ទៈរួមគ្នាដែលរឹងមាំជាងមុន និងសកម្មភាពដ៏ស្អិតរមួតរបស់យើងនោះទេ ទើបអាចឱ្យយើងតម្រែតម្រង់តំបន់



ទិដ្ឋភាពក្នុងពិធីបើកមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣




*ថ្នាក់ដឹកនាំជាន់ខ្ពស់កម្ពុជាថតរូបអនុស្សាវរីយ៍ជាមួយប្រធានសភាបណ្តាប្រទេសសមាជិក AIPA*

របស់យើង ដោះស្រាយរាល់បញ្ហាប្រឈមជាច្រើន ដែលតំបន់អាស៊ានយើងកំពុងជួបប្រទះ។ នៅពេលដែលយើងកំពុងងើបឡើងវិញពីជំងឺរាតត្បាតកូវីដ-១៩ និងផលប៉ះពាល់ដែលកើតចេញពីវិបត្តិកូវីដ-១៩ បញ្ហាប្រឈមជាអាទិភាពជាច្រើនកំពុងទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ពីយើងទាំងអស់គ្នា ដែលរួមមានភាពអាសន្ននៃការប្រែប្រួលអាកាសធាតុ ការកើនឡើង នៃភាពតានតឹងភូមិសាស្ត្រនយោបាយ ជម្លោះប្រដាប់អាវុធ អតិផរណាខ្ពស់នាំឱ្យតម្លៃនៃការរស់នៅកើនឡើងខ្ពស់ កង្វះខាតថាមពលដែលនាំឱ្យកំណើនវិសមភាពក្នុងសង្គម និងអត្រាភាពក្រីក្រកាន់តែអាក្រក់។ បញ្ហាទាំងអស់នេះ ប្រសិនបើមិនត្រូវបានដោះស្រាយទាន់ពេលវេលានោះទេ ប្រាកដជានឹងបន្ទុចបង្អាក់យ៉ាងធ្ងន់ធ្ងរដល់កិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញរបស់យើង ព្រមទាំងបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់។

សម្តេចប្រធានព្រឹទ្ធសភារំលឹកថា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ យើងត្រូវធានាថាសហគមន៍អាស៊ានរបស់យើងមានចីរភាព បរិយាបន្ន និងភាពធន់។ អាស្រ័យហេតុដូចនេះហើយ មូលបទនៃមហាសន្និបាតអាយប៉ាលើកទី៤៣ គឺ “បោះជំហានជាមួយគ្នាដើម្បីចីរភាព បរិយាបន្ន និងភាពធន់របស់អាស៊ាន”។ មូលបទនេះ គូសបញ្ជាក់អំពីភាពចាំបាច់របស់យើងទាំងអស់គ្នាក្នុងការធ្វើសកម្មភាពរួមគ្នា ក្នុងស្មារតីឯកភាពអាស៊ាន ដើម្បីដោះស្រាយរាល់បញ្ហាប្រឈមរួមរបស់យើង។ ភាពជាដៃគូសភារបស់យើងត្រូវតែពង្រឹងពង្រីកបន្ថែមទៀត ដើម្បីឱ្យយើងសម្រេចបាននូវសហគមន៍អាស៊ាន ដែលអាចផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនរបស់យើងទាំងអស់គ្នាក្នុងជំនាន់នេះ និងជំនាន់ក្រោយៗទៀត។

ក្នុងន័យនេះ យើងទាំងអស់គ្នាជាសមាជិកសភាអាយប៉ាត្រូវចាប់យកឱកាសនេះ ដើម្បីធ្វើសកម្មភាពតាមរយៈភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការសភារបស់យើងជាកម្លាំងរួម ដើម្បីសម្រេចបានផលប្រយោជន៍រួម។ តាមរយៈអាយប៉ា យើងត្រូវជំរុញសហថាមពលកាន់តែខ្លាំងក្លាជាមួយនឹងរដ្ឋាភិបាល ដើម្បីជំរុញការស្តារឡើងវិញប្រកបដោយចីរភាព គាំទ្រដល់ការអភិវឌ្ឍ ដើម្បីប្រជាជន និងផ្តោតលើប្រជាជនដោយមិនទុកនរណាម្នាក់ចោល និងកសាងសង្គមប្រកបដោយភាពធន់ដែលអាចត្រៀមខ្លួនទប់ទល់នឹងវិបត្តិនាពេលអនាគត។

ក្នុងនាមសភាកម្ពុជា សម្តេចសូមប្រសិទ្ធពរឱ្យមហាសន្និបាតអាយប៉ាលើកទី៤៣ ប្រព្រឹត្តទៅដោយទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា និងជោគជ័យដ៏ធំធេង និងសូមប្រសិទ្ធពរជ័យជូនសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់មានសុខភាពល្អ និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយផាសុកភាព៕

(អត្ថបទ៖ ទេព មករា រូបភាព៖ ធុន គីមជី)

# សម្ដេចប្រធានព្រឹទ្ធសភាទទួលជួបនាយករដ្ឋមន្ត្រីវៀតណាម





*ឯកឧត្តម ផាម មិញជីញ និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នារសៀលថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង១៤:៣០នាទី នៅវិមានព្រឹទ្ធសភា សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបជាមួយនឹងឯកឧត្តម **ផាម មិញជីញ** (Pham Minh Chin) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយម-វៀតណាម ក្នុងឱកាសដែលឯកឧត្តម **ផាម មិញជីញ** ដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការ និងចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំពាក់ព័ន្ធ នៅរាជធានីភ្នំពេញ។

ក្នុងនាមព្រឹទ្ធសភា ប្រជាជនកម្ពុជា និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវសេចក្ដីរីករាយ និងស្វាគមន៍ដ៏កក់ក្ដៅ ជូនចំពោះឯកឧត្តម **ផាម មិញជីញ** និងគណៈប្រតិភូ ដែលមានឱកាសបានជួបសារជាថ្មីម្ដងទៀតនៅរាជធានីភ្នំពេញ បន្ទាប់ពីបានជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម **ផាម មិញជីញ** កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ នៅទីក្រុងហាណូយ កន្លងទៅថ្មីៗ។ ការជួបគ្នាញឹកញាប់រវាងថ្នាក់ដឹកនាំ នៃប្រទេសទាំងពីរ ពិតជាមានសារៈសំខាន់ណាស់ចំពោះសភាពការណ៍នាពេលបច្ចុប្បន្ន។ តាមរយៈដំណើរទស្សនកិច្ចរបស់ឯកឧត្តម និងគណៈប្រតិភូក្នុងឱកាសនេះ ពិតជាបានរួមចំណែកដ៏ធំធេងដល់ការថែរក្សាពូនជ្រំនូវចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ និងផ្ដល់ការគាំទ្រដល់តួនាទីកម្ពុជាជាប្រធានអាស៊ាន។

ក្នុងឱកាសនោះ ឯកឧត្តម **ផាម មិញជីញ** បានពាំនាំ



*ទិដ្ឋភាពក្នុងពិធីជំនួបសម្ដែងការគួរសម*



*ទិដ្ឋភាពក្នុងពិធីជំនួបសម្តែងការគួរសម*

នូវការសួរសុខទុក្ខពីឯកឧត្តមអគ្គលេខាធិការបក្សកុម្មុយ-នីស្តវៀតណាម ឯកឧត្តមប្រធានរដ្ឋវៀតណាម និងឯកឧត្តមប្រធានរដ្ឋសភាវៀតណាម ជូនចំពោះសម្តេចប្រធានព្រឹទ្ធ-សភា និងសមាជិក សមាជិកាព្រឹទ្ធសភាកម្ពុជា។ ឯកឧត្តមបានបញ្ជាក់ថា ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ គឺជាទំនាក់ទំនងមួយដែលគ្មានកម្លាំងអមិត្តណាមួយមកបំបែកបំបាក់បានឡើយ។ ជាមួយគ្នានោះ ឯកឧត្តមបានសម្តែងនូវការអបអរសាទរចំពោះសមិទ្ធផលនានា ដែលប្រទេសកម្ពុជាសម្រេចបាន ក្រោមការដឹកនាំរបស់ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ធ្វើឱ្យប្រទេសកម្ពុជាមានការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ដែលធ្វើឱ្យប្រជាជនកម្ពុជាមានជីវភាពរស់នៅយ៉ាងល្អប្រសើរ។

ឯកឧត្តម **ផាម មិញជីញ** បានបញ្ជាក់ថា ប្រទេសវៀតណាមគាំទ្រជានិច្ចដល់តួនាទីកម្ពុជាជាប្រធានអាស៊ាន និងសង្ឃឹមថា ប្រទេសកម្ពុជានឹងទទួលបានជោគជ័យក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំ AIPA លើកទី៤៣។

ដោយមើលឃើញអំពីសារៈសំខាន់នៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើវិស័យនយោបាយ ការបរទេស វិនិយោគ និងពាណិជ្ជកម្ម ឯកឧត្តម **ផាម មិញជីញ** បានស្នើសុំឱ្យជំរុញសកម្មភាពលើគ្រប់វិស័យ និងការផ្លាស់ប្តូរដំណើរទស្សនកិច្ចគ្នាទៅវិញទៅមក ដើម្បីឈ្វេងយល់អំពីគ្នាបន្ថែមទៀត ក្នុងបរិបទដែលសភាពការណ៍ក្នុងតំបន់ និងពិភពលោកមានការប្រែប្រួលដូចពេលបច្ចុប្បន្ននេះ។

ឯកឧត្តម **ផាម មិញជីញ** សង្ឃឹមថា ស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ នឹងមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើងថែមទៀត និងគាំទ្រដល់ទំនាក់ទំនងរដ្ឋាភិបាល នៃប្រទេសទាំងពីរ ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ហើយសភា នៃប្រទេសទាំងពីរតែងតែគាំទ្រគ្នាទៅវិញទៅ-មកលើរាល់បញ្ហាពហុភាគី ទាំងក្នុងតំបន់ និងពិភពលោក។ ឯកឧត្តមមានជំនឿជឿជាក់ថា ទំនាក់ទំនង និងកិច្ចសហប្រតិ-បត្តិការរវាងរដ្ឋាភិបាល និងរដ្ឋសភាវៀតណាម ជាមួយនឹងសភាកម្ពុជា នឹងកាន់តែរីកចម្រើនថែមទៀតនាពេលខាងមុខ។

សម្តេចប្រធានព្រឹទ្ធសភាបានអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហការដ៏ល្អរវាងប្រទេសទាំងពីរ ក្នុងការរៀបចំព្រឹត្តិការណ៍សំខាន់ៗជាច្រើនដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៥៥ឆ្នាំ ថ្ងៃបង្កើតទំនាក់ទំនងការទូត និងឆ្នាំមិត្តភាពកម្ពុជា-វៀតណាម។ សម្តេចបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដ៏ធំធេងលើគ្រប់វិស័យ និងគ្រប់កម្រិតដែលប្រទេសទាំងពីរសម្រេចបានក្នុងរយៈពេល៥៥ឆ្នាំកន្លងទៅ ដែលបាននាំមកនូវឯករាជ្យភាព អធិបតេយ្យភាព សន្តិ-ភាព ស្ថិរភាព និងការអភិវឌ្ឍ ហើយបានផ្តល់ផលប្រយោជន៍

ដ៏ធំធេងទៅវិញទៅមកសម្រាប់ប្រជាជនទាំងពីរ។

សម្ដេចប្រធានព្រឹទ្ធសភាបានគាំទ្រ និងលើកទឹកចិត្តឱ្យរដ្ឋាភិបាល នៃប្រទេសទាំងពីរអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលនូវរាល់កិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់គ្នាដែលបានចុះហត្ថលេខារួចហើយ ដែលរួមចំណែកលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍប្រទេសជាតិ។ ជាមួយគ្នានោះ សម្ដេចបានអបអរសាទរចំពោះសាធារណរដ្ឋសង្គមនិយមវៀតណាម សម្រេចបានកំណើនសេដ្ឋកិច្ចរហូតដល់៨,៨% ក្នុងត្រីមាសទី៣នេះ ដែលជាអត្រាខ្ពស់ជាងគេនៅក្នុងតំបន់។

សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការគាំទ្រ និងអបអរសាទរដែលរដ្ឋាភិបាលទាំងពីរបានចុះហត្ថលេខាលើឯកសារសំខាន់ៗចំនួន ១១ឯកសារ នៅក្នុងដំណើរទស្សនកិច្ចរបស់ឯកឧត្ដមនាយករដ្ឋមន្ត្រីវៀតណាម។ ព្រឹទ្ធសភា និងខ្លួនសម្ដេចផ្ទាល់ បន្តគាំទ្រទាំងស្រុង និងលើកទឹកចិត្តដល់រដ្ឋាភិបាលទាំងពីរអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវយន្តការនានាដែលមានស្រាប់ និងកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់ដែលរដ្ឋាភិបាល នៃប្រទេសទាំងពីរបានសម្រេចរួមគ្នាកន្លងទៅ និងបន្តគាំទ្រដល់ទិសដៅកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដែលបម្រើផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមកសម្រាប់ប្រជាជន នៃប្រទេសទាំងពីរ។

សម្ដេចប្រធានព្រឹទ្ធសភាបានអះអាងជាថ្មីថា ទោះបីស្ថានភាពតំបន់ និងអន្តរជាតិមានការវិវឌ្ឍ ប្រែប្រួលយ៉ាងឆាប់រហ័ស ហើយស្មុគស្មាញ និងប្រកបដោយគ្រោះថ្នាក់ក៏ដោយ ក៏ពុំមានកម្លាំងណាអាចបំបែកបំបាក់សាមគ្គីភាព មិត្តភាពរវាងប្រទេសទាំងពីរបានឡើយ ទាំងពេលបច្ចុប្បន្ន និងពេលអនាគតយូរអង្វែង។ កម្ពុជាប្រកាន់ខ្ជាប់ខ្ជួនឥតងាករេចាត់ទុកវៀតណាមជា “អ្នកជិតខាងល្អ មិត្តភក្តិល្អ បងប្អូនល្អ និងដៃគូល្អ”។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ព្រឹទ្ធសភាកម្ពុជា និងរដ្ឋសភាវៀតណាម មានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អ ដែលស្ដែងចេញតាមរយៈការផ្លាស់ប្ដូរទស្សនកិច្ចគ្រប់កម្រិតទៅវិញទៅមកជាញឹកញាប់ និងការបន្តគាំទ្រគ្នាទៅវិញទៅមកជាបន្តបន្ទាប់នៅក្នុងកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ នៃអន្តរសភា ដូចជា៖ IPU, AIPA, CLV-DTA, APPF, APF, ASEPជាដើម។ ក្រៅពីមុខងារស្នូលរបស់សភា និងកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ សភា នៃប្រទេសទាំងពីរមានភារកិច្ចរួមចំណែកការពារ ថែរក្សា ពូនជ្រំចំណងសាមគ្គីភាព មិត្តភាពរវាងប្រទេសទាំងពីរឱ្យរឹងមាំស្ថិតស្ថេរ និងជំរុញការផ្សព្វផ្សាយដល់យុវជនជំនាន់ក្រោយឱ្យបានយល់ដឹងច្បាស់អំពីសារៈសំខាន់ នៃប្រវត្តិសាស្ត្រដ៏មានតម្លៃរវាងកម្ពុជា-វៀតណាម សម្រាប់បន្តវេននាពេលអនាគត។

ជាមួយគ្នានោះ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងការអបអរសាទរដ៏ស្មោះស្ម័គ្រចំពោះសមិទ្ធផលដ៏ធំធេងដែលបក្សកុម្មុយនីស្តវៀតណាម រដ្ឋាភិបាល និងប្រជាជនវៀតណាមសម្រេចបានក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ខ្លួន។ សម្ដេចមានជំនឿជឿជាក់ថា ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនីស្តវៀតណាម រដ្ឋាភិបាល និងសភាវៀតណាម វៀតណាមនឹងបន្តសម្រេចបាននូវសមិទ្ធផលសង្គមសេដ្ឋកិច្ចធំៗបន្ថែមទៀត និងឈានឆ្ពោះទៅសម្រេចបាននូវគោលដៅ “ក្លាយទៅជាប្រទេសអភិវឌ្ឍន៍មានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៤៥”។

សម្ដេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនឯកឧត្តមនាយករដ្ឋមន្ត្រី និងគណៈប្រតិភូ សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបានជោគជ័យ និងភាពរីករាយក្នុងពេលស្នាក់អាស្រ័យនៅរាជធានីភ្នំពេញ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ ធុន គីមជី)

# សម្ដេចប្រធានព្រឹទ្ធសភាទទួលជួបជាមួយឯកឧត្តមអនុប្រធានាធិបតីឥណ្ឌា





*ឯកឧត្តម JAGDEEP DHANKHAR និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នារសៀលថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង ១៥:០០នាទី នៅវិមានព្រឹទ្ធសភា សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានជួបសវនាការជាមួយនឹងឯកឧត្តម JAGDEEP DHANKHAR អនុប្រធានាធិបតី និងជាប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋឥណ្ឌា ក្នុងឱកាសដែលឯកឧត្តមអនុប្រធានាធិបតី ដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាលើកទី១៩ នៅរាជធានីភ្នំពេញ។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាមានសេចក្ដីសោមនស្សរីករាយ និងស្វាគមន៍យ៉ាងកក់ក្ដៅចំពោះឯកឧត្តមអនុប្រធានាធិបតី និងគណៈប្រតិភូដែលបានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាលើកទី១៩ តបតាមការអញ្ជើញរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ការអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌារបស់ឯកឧត្តម និងគណៈប្រតិភូ បានឆ្លុះបញ្ចាំងពីការគាំទ្រតួនាទីរបស់កម្ពុជាជាប្រធានអាស៊ាន និងទំនាក់ទំនងដ៏ជិតស្និទ្ធ នៃភាពជាដៃគូអាស៊ាន-ឥណ្ឌា ព្រមទាំងរួមចំណែកពង្រឹងពង្រីកចំណងមិត្តភាព កិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រជាជន និងប្រទេសទាំងពីរ។

ក្នុងឱកាសនោះ ឯកឧត្តម JAGDEEP DHANKHAR បានសម្ដែងនូវសេចក្ដីរីករាយដែលបានមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ដែលប្រជាជន និងប្រទេសទាំងពីរបានឆ្លុះបញ្ចាំងអំពីវប្បធម៌ អរិយធម៌រួមគ្នា ដែលមានតាំងពីយូរលង់ណាស់មកហើយ។ ឯកឧត្តមបានរំលឹកថា ប្រទេសទាំងពីរបានបង្កើតទំនាក់ទំនងការទូតជាមួយគ្នាតាំងពីឆ្នាំ១៩៥២មក។ ទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ត្រូវបានពង្រឹងពង្រីកជាបន្តបន្ទាប់។ ជាងនេះទៅទៀត ប្រទេសទាំងពីរបានប្រារព្ធខួបអនុស្សាវរីយ៍លើកទី៧០ឆ្នាំ នៃថ្ងៃបង្កើតទំនាក់ទំនងការទូតកម្ពុជា-ឥណ្ឌា និងខួបអនុស្សាវរីយ៍លើកទី៣០ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-ឥណ្ឌា។

ឯកឧត្តមអនុប្រធានាធិបតីបានបញ្ជាក់ថា ក្នុងបរិបទនៃគោលនយោបាយធ្វើសកម្មភាពឆ្ពោះទៅទិសខាងកើតរបស់ប្រទេសឥណ្ឌា អាស៊ានបានដើរតួនាទីយ៉ាងសំខាន់ ជាពិសេសប្រទេសកម្ពុជា។ ប្រទេសឥណ្ឌាបានខិតខំប្ដេជ្ញាចិត្តធ្វើយ៉ាងណាអនុវត្ត និងផ្សារភ្ជាប់នូវគោលនយោបាយធ្វើសកម្មភាពឆ្ពោះទៅទិសខាងកើត ជាពិសេសតាមរយៈគំនិតផ្ដួចផ្ដើមនានា ដើម្បីរួមចំណែកក្នុងកិច្ចសហប្រតិបត្តិការអាស៊ាន-ឥណ្ឌា និងកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា។

ឯកឧត្តមអនុប្រធានាធិបតីបានសម្ដែងនូវការអបអរសាទរចំពោះប្រទេសកម្ពុជា ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ កិច្ចប្រជុំពាក់ព័ន្ធ និងកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌា ដែលបានបញ្ចប់ទៅដោយ





*ទិដ្ឋភាពក្នុងពិធីជួបសម្ដែងការគួរសម*

ជោគជ័យ។ ជាមួយគ្នានោះ ឯកឧត្ដមបានជម្រាបជូនសម្ដេចប្រធានព្រឹទ្ធសភាជ្រាបថា នាពេលខាងមុខនេះ ឯកឧត្ដមអនុប្រធានរដ្ឋសភាឥណ្ឌានឹងដឹកនាំគណៈប្រតិភូមកចូលរួមមហាសន្និបាតអន្តរសភា (AIPA) លើកទី៤៣ នៅប្រទេសកម្ពុជា។

ឯកឧត្ដមអនុប្រធានាធិបតីបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងសភានៃប្រទេសទាំងពីរ និងក្រុមមិត្តភាពទ្វេភាគី នៃសភាប្រទេសទាំងពីរ។ ឆ្លៀតឱកាសនោះដែរ ឯកឧត្ដមបានគោរពអញ្ជើញសម្ដេចប្រធានព្រឹទ្ធសភាទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋឥណ្ឌាក្នុងពេលវេលាសមស្របណាមួយ។

សម្ដេចប្រធានព្រឹទ្ធសភាបានរំលឹកអំពី ទំនាក់ទំនងមិត្តភាពជាប្រពៃណីរវាងប្រទេសទាំងពីរ ដែលមានតាំងពីយូរលង់ណាស់មកហើយ ដែលបានបង្ហាញច្បាស់តាមរចនាបថនៃប្រាង្គប្រាសាទនានានៅកម្ពុជា។ ចាប់តាំងពីប្រទេសទាំងពីរបានបង្កើតទំនាក់ទំនងការទូតតាំងពីឆ្នាំ១៩៥២មក ទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ត្រូវបានពង្រឹងពង្រីកជាបន្តបន្ទាប់ តាមរយៈការផ្លាស់ប្ដូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ ក្រសួងស្ថាប័ននានា និងការផ្លាស់ប្ដូររវាងប្រជាជន និងប្រជាជននៃប្រទេសទាំងពីរ ព្រមទាំងទំនាក់ទំនងក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលមិនគ្រាន់តែនាំមកនូវវឌ្ឍនភាព វិបុលភាពដ៏ធំធេងសម្រាប់ប្រជាជន និងប្រទេសទាំងពីរតែប៉ុណ្ណោះទេ គឺនៅបានរួមចំណែកយ៉ាងសំខាន់ដល់ការថែរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍនៅក្នុងតំបន់ និងអន្តរជាតិផងដែរ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា និមិត្តរូបនៃចំណងមិត្តភាពកម្ពុជា ឥណ្ឌា ដែលប្រជាជនកម្ពុជាចងចាំជានិច្ចនោះគឺ នៅភ្នំពេញមានដាក់តាំងរូបសំណាកលោកមហាត្មះ គន្ធី មហាវិថីប្រសិទ្ធនាមលោក ហ្សាវ៉ាហារឡាល នេហ៌រុ និងដើមពោធិព្រឹក្សដែលនាំមកពីប្រទេសឥណ្ឌាត្រូវបានប្រជាជននាំយកទៅដាំដុះនៅតាមបណ្ដាខេត្តទូទាំងប្រទេសកម្ពុជា។

សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាធារណរដ្ឋឥណ្ឌាដែលបានគាំទ្របុព្វហេតុដ៏ត្រឹមត្រូវ និងយុត្តិធម៌របស់កម្ពុជាតាំងពីឆ្នាំ១៩៨១ ក្នុងកាលៈទេសៈដែលកម្ពុជាកំពុងជួបការលំបាកបំផុត ក្រោយពីបានរំដោះប្រទេសជាតិពីរបបប្រល័យពូជសាសន៍ និងត្រូវបានគេហ៊ុមព័ទ្ធទាំងខាងនយោបាយ និងសេដ្ឋកិច្ច។ ជាមួយគ្នានោះ សម្ដេចក៏បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលឥណ្ឌា ដែលបានផ្ដល់ជំនួយសប្បុរសធម៌នូវវ៉ាក់សាំងប្រភេទកូវីស្សែលចំនួន៣២៥.០០០ដូស ក្រោមគំនិតផ្ដួចផ្ដើមចតុភាគី (QUAD)។

សម្ដេចប្រធានព្រឹទ្ធសភាបានធ្វើការកត់សម្គាល់ដោយសេចក្ដីពេញចិត្ត ចំពោះកិច្ចសហប្រតិបត្តិការអាស៊ានឥណ្ឌា និងកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា មានវឌ្ឍនភាពដ៏ល្អ



*ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម*

ប្រសើរ។ ក្នុងនោះឥណ្ឌាជួយទ្រទ្រង់គម្រោងទទួលផលឆាប់រហ័ស (QIP) និងកិច្ចសហប្រតិបត្តិការឥណ្ឌា-CLMV។ ចាប់តាំងពីឆ្នាំ២០១៥-២០២២ កម្ពុជាទទួលបានគម្រោងលើវិស័យកសិកម្ម បរិស្ថាន សុខាភិបាល ការអភិវឌ្ឍជនបទ អប់រំ ការលើកកម្ពស់ស្ត្រី និងវប្បធម៌ ចំនួន៤៦គម្រោង ក្នុងនោះ ២១គម្រោងបានបញ្ចប់ និង២៥គម្រោងទៀតបាននឹងកំពុងអនុវត្ត។

ឆ្លៀតក្នុងឱកាសនោះ សម្តេចប្រធានព្រឹទ្ធសភាបានជម្រាបជូនឯកឧត្តមអនុប្រធានាធិបតីជ្រាបអំពី មុខងារស្នូលរបស់ព្រឹទ្ធសភាកម្ពុជាមានចំនួនបី គឺ**១**-មុខងារនីតិកម្ម **២**-មុខងារតំណាង និង**៣**-មុខងារតាមដានការអនុវត្តច្បាប់។ ឈរលើមុខងារស្នូលទាំងបីនេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួន បម្រើឧត្តមប្រយោជន៍ជាតិ ការពារសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ជំរុញ និងលើកកម្ពស់គោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស នីតិរដ្ឋ ធានាស្ថិរភាពនយោបាយ សន្តិភាព សណ្តាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយវឌ្ឍនភាព។ សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងសភាឥណ្ឌា ដែលបានជួយ និងបន្តជួយអភិវឌ្ឍធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា តាមរយៈការទៅធ្វើកម្មសិក្សានៅប្រទេសឥណ្ឌា និងការបញ្ជូនអ្នកជំនាញការឥណ្ឌាមកបណ្តុះបណ្តាលផ្ទាល់នៅកម្ពុជា។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទាំងពីរបានឯកភាពបន្តអនុស្សរណៈយោគយល់គ្នា ហើយបច្ចុប្បន្ននេះកំពុងរង់ចាំពេលវេលាសមស្របដើម្បីចុះហត្ថលេខា។

ជាទិសដៅខាងមុខ សម្តេចប្រធានព្រឹទ្ធសភាបានស្នើដល់ព្រឹទ្ធសភាឥណ្ឌាពិចារណាលើ៣ចំណុច រួមមាន៖

**១-ព្រឹទ្ធសភាទាំងពីរជំរុញការបង្កើនការផ្លាស់ប្តូរដំណើរទស្សនកិច្ចគ្រប់កម្រិតឱ្យបានញឹកញាប់ ដើម្បីផ្លាស់ប្តូរបទពិសោធន៍លើវិស័យនៃគណៈកម្មការជំនាញរបស់ព្រឹទ្ធសភាទាំងពីរ និងជួយគាំទ្រគ្នានៅទៅវិញទៅមកនៅក្នុងក្របខ័ណ្ឌអន្តរសភាតំបន់ និងអន្តរជាតិ។**

**២-បន្តជួយអភិវឌ្ឍធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា តាមរយៈកម្មសិក្សា និងអាហារូបករណ៍ ឬឥណ្ឌាបញ្ជូនអ្នកជំនាញឥណ្ឌាមកបណ្តុះបណ្តាលផ្ទាល់នៅកម្ពុជា។**

**៣-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទាំងពីរ រៀបចំពេលវេលាសមស្រប ដើម្បីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នារវាងព្រឹទ្ធសភាកម្ពុជា និងព្រឹទ្ធសភាឥណ្ឌា។**

ឆ្លើយតបនឹងការអញ្ជើញរបស់ឯកឧត្តមអនុប្រធានាធិបតី សម្តេចប្រធានព្រឹទ្ធសភាសន្យាថា នឹងជ្រើសរកពេលវេលាសមស្រប ដើម្បីបំពេញទស្សនកិច្ចនៅសាធារណរដ្ឋឥណ្ឌា។

សម្តេចបានប្រសិទ្ធពរជូនឯកឧត្តម និងគណៈប្រតិភូមានសុខភាពល្អ ទទួលបានជោគជ័យ និងរីករាយក្នុងការស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)

# សម្ដេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្ដមប្រធានរដ្ឋសភាវៀតណាម




*ឯកឧត្ដម វឿង ឌិញហ្វេ និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នារសៀលថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង ១៤:៣០នាទី នៅវិមានព្រឹទ្ធសភា សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបឯកឧត្ដម **វឿង ឌិញហ្វេ** (VUONG DINH HUE) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងឱកាសដែលឯកឧត្ដម **វឿង ឌិញហ្វេ** ដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការ និងអញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី ៤៣ នៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមព្រឹទ្ធសភា ក្នុងនាមសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការស្វាគមន៍យ៉ាងកក់ក្ដៅចំពោះឯកឧត្ដម **វឿង ឌិញហ្វេ** និងគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការ និងអញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅព្រះរាជាណាចក្រកម្ពុជា។

សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវសេចក្ដីរីករាយដែលមានឱកាសបានជួបឯកឧត្ដម **វឿង ឌិញហ្វេ** សារជាថ្មីម្ដងទៀតនៅរាជធានីភ្នំពេញ បន្ទាប់ពីបានជួបពិភាក្សាការងារគ្នាកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ នៅទីក្រុងហាណូយ កន្លងទៅថ្មីៗនេះ។ ការជួបគ្នាញឹកញាប់រវាងថ្នាក់ដឹកនាំ នៃប្រទេសទាំងពីរ ពិតជាមានសារៈសំខាន់ណាស់ចំពោះសភាពការណ៍នាពេលបច្ចុប្បន្ននេះ។ តាមរយៈដំណើរទស្សនកិច្ចរបស់ឯកឧត្ដម **វឿង ឌិញហ្វេ** និងគណៈប្រតិភូ ពិតជាបញ្ជាក់ឱ្យឃើញច្បាស់អំពីការយកចិត្តទុកដាក់ខ្ពស់ដល់ការថែរក្សាពូនជ្រំចំណងមិត្តភាព សាមគ្គីភាព និងសហប្រតិបត្តិការរវាងប្រទេស សភា និងប្រជាជនទាំងពីរ ដែលមានជាយូរលង់មកហើយ ឱ្យកាន់តែរឹងមាំ ស្ថិតស្ថេរ យូរអង្វែង។

ក្នុងឱកាសនោះ ឯកឧត្ដម **វឿង ឌិញហ្វេ** បានសម្ដែងនូវសេចក្ដីរីករាយដែលបានដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការលើកទី១ នៅព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាប្រធានរដ្ឋសភាវៀតណាម។ ក្នុងដំណើរទស្សនកិច្ច និងការចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ គឺជាសក្ខីភាពបញ្ជាក់យ៉ាងច្បាស់អំពីការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ ក្នុងនាមជាមិត្តល្អ ជាបងប្អូនល្អ ជាអ្នកជិតខាងល្អ និងជាដៃគូល្អ ស្របតាមពាក្យស្លោក "ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ស្ថិរភាពយូរអង្វែង"។

ឯកឧត្ដមប្រធានរដ្ឋសភាវៀតណាម បានសម្ដែងនូវការអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានា និងការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជាដែលសម្រេចបាននាពេលកន្លងទៅ ជាពិសេសប្រទេសកម្ពុជាទទួលបានជោគជ័យក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំពាក់ព័ន្ធ។ ឯកឧត្ដមមានជំនឿជឿជាក់ថា សភាកម្ពុជានឹងទទួលបានជោគជ័យក្នុងការរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣នាពេលខាងមុខនេះ។




*ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម*

ឯកឧត្តមប្រធានរដ្ឋសភាវៀតណាមបានបញ្ជាក់ថា ការអនុវត្តតាមស្មារតីនៃជំនួបជាមួយនឹងសម្តេចប្រធានព្រឹទ្ធសភានាពេលកន្លងទៅ ខុទ្ទកាល័យរដ្ឋសភាវៀតណាមនឹងចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នាជាមួយនឹងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា នាពេលបន្តិចទៀតនេះ ដើម្បីរួមចំណែកក្នុងការពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងសភា នៃប្រទេសទាំងពីរ។

ឯកឧត្តមប្រធានរដ្ឋសភាវៀតណាមសង្ឃឹមថា ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងរដ្ឋាភិបាល និងរដ្ឋសភាវៀតណាម ជាមួយនឹងសភាកម្ពុជា និងប្រជាជននៃប្រទេសទាំងពីរកាន់តែរីកចម្រើនថែមទៀតនាពេលខាងមុខ។ ឯកឧត្តមបានបញ្ជាក់ថា រដ្ឋសភាវៀតណាមនឹងខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំបន្ថែមទៀត។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវសេចក្តីពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហការដ៏ល្អរវាងប្រទេសទាំងពីរ ក្នុងការរៀបចំព្រឹត្តិការណ៍សំខាន់ៗជាច្រើន ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៥៥ឆ្នាំ ថ្ងៃបង្កើតទំនាក់ទំនងការទូត និងឆ្នាំមិត្តភាពកម្ពុជា-វៀតណាម។ សម្តេចបានវាយតម្លៃខ្ពស់ និងអបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលទាំងពីរក្នុងការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដែលបានរួមចំណែកដ៏សំខាន់ដល់កំណើនសេដ្ឋកិច្ច និងវិបុលភាពរួម។ ជាមួយគ្នានោះ សម្តេចក៏បានអបអរសាទរចំពោះសមិទ្ធផលថ្មីដែលរដ្ឋាភិបាលទាំងពីរបានចុះហត្ថលេខាលើឯកសារតួបករណ៍សំខាន់ៗ ចំនួន១១ឯកសារបន្ថែមទៀត ក្នុងឱកាសទស្សនកិច្ចជាផ្លូវការរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីវៀតណាម នៅព្រះរាជាណាចក្រកម្ពុជាកន្លងទៅថ្មីៗនេះ។

សម្តេចប្រធានព្រឹទ្ធសភាបានកត់សម្គាល់ឃើញថា ក្នុងកាលៈទេសៈដែលពិភពលោកកំពុងរងនូវវិបត្តិសេដ្ឋកិច្ចសកល សន្តិសុខស្បៀង និងថាមពល ប្រទេសទាំងពីររក្សាបាននូវកំណើនសេដ្ឋកិច្ចវិជ្ជមាន និងនាំមុខនៅក្នុងតំបន់។ ប្រទេសទាំងពីរគួរគប្បីខិតខំបន្ថែមទៀត ទាញយកប្រយោជន៍ឱ្យអស់សក្តានុពលពីយន្តការកិច្ចសហប្រតិបត្តិការដែលមានស្រាប់ ដើម្បីបង្កើនទំហំការផ្លាស់ប្តូរពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍បន្ថែមទៀត ដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់អតិផរណា ពង្រឹងភាពជាម្ចាស់ ឯករាជ្យភាព ទប់ស្កាត់ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងពីខាងក្រៅ និងទប់ស្កាត់ឧបាយកលរបស់ពួកអមិត្តដែលប៉ុនប៉ងបំបែកបំបាក់ចំណងមិត្តភាព សាមគ្គីភាព នៃប្រទេសទាំងពីរ។ ទន្ទឹមគ្នានោះ សម្តេចបានបញ្ជាក់ថា ប្រទេសកម្ពុជាចាត់ទុកវៀតណាម គឺជាមិត្តល្អ ជាបងប្អូនល្អ ជាអ្នកជិតខាងល្អ និងជាដៃគូល្អ តាមពាក្យស្លោក "ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ស្ថិរភាពយូរអង្វែង"។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការអបអរសាទរសភាប្រទេសទាំងបី កម្ពុជា-ឡាវ-វៀតណាម ដែលបានសម្រេចដំឡើងកម្រិត នៃកិច្ចប្រជុំតំបន់ត្រីកោណអភិវឌ្ឍន៍ (CLV-DTA) ពីកម្រិតប្រធានគណៈកម្មការកិច្ចការបរទេសទៅកម្រិតប្រធានសភា ដែលកិច្ចប្រជុំប្រព្រឹត្តទៅពីរឆ្នាំម្តង

ហើយប្រទេសឡាវនឹងធ្វើជាប្រធានកិច្ចប្រជុំនៅឆ្នាំ២០២៣ ខាងមុខ។

ក្នុងនាមព្រឹទ្ធសភា ក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានផ្តល់ជំនួយជាសម្ភារបរិក្ខារការិយាល័យ ដល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា។ ជំនួយរបស់រដ្ឋសភាវៀតណាមក្នុងពេលកន្លងទៅ និងក្នុងពេលនេះ បានរួមចំណែកក្នុងដំណើរការការងាររបស់ព្រឹទ្ធសភាប្រកបដោយប្រសិទ្ធភាព ហើយព្រឹទ្ធសភាកម្ពុជានឹងបន្តប្រើប្រាស់ជំនួយនេះប្រកបដោយគណនេយ្យភាព។

សម្តេចប្រធានព្រឹទ្ធសភាបានជម្រាបឯកឧត្តម **វឿង ឌិញហ្វេ** ជ្រាបថា កិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១និងកិច្ចប្រជុំពាក់ព័ន្ធ បានបញ្ចប់ទៅប្រកបដោយជោគជ័យ ដើម្បីធានាសន្តិភាព ស្ថិរភាព ការអភិវឌ្ឍនៅក្នុងគ្រួសារអាស៊ាន ក៏ដូចជារួមចំណែកកសាងសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍក្នុងតំបន់ និងអន្តរជាតិទាំងមូលផងដែរ។

សម្តេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនឯកឧត្តម **វឿង ឌិញហ្វេ** និងគណៈប្រតិភូ មានសុខភាពល្អបរិបូរណ៍ និងទទួលបានការរីករាយក្នុងពេលស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីជំនួបពិភាក្សាទ្វេភាគីរួចមក សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **វឿង ឌិញហ្វេ** ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានអញ្ជើញជាអធិបតីភាពក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជាជាមួយនឹងខុទ្ទកាល័យរដ្ឋសភាវៀតណាម ដែលចុះហត្ថលេខាដោយឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាកម្ពុជា និងឯកឧត្តម Bui Van Cuong ប្រធានខុទ្ទកាល័យរដ្ឋសភាវៀតណាម។

អនុស្សរណៈនេះរៀបចំឡើងក្នុងគោលបំណងដើម្បីរួមចំណែកក្នុងការពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-វៀតណាម និងលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងសេនាធិការរបស់សភា នៃប្រទេសទាំងពីរឱ្យទទួលបានលទ្ធផលជាវិជ្ជមាន ព្រមទាំងភាគីទាំងពីរបន្តពង្រឹងសាមគ្គីភាព និងជំរុញកិច្ចសហប្រតិបត្តិការក្នុងទម្រង់ផ្សេងៗ ដើម្បីគាំទ្រដល់សភាទាំងពីរ និងគណៈកម្មការសភា នៃប្រទេសទាំងពីរ ក្នុងការអនុវត្តមុខងារ និងភារកិច្ចដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ប្រទេសនីមួយៗ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*ទិដ្ឋភាពក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈ*



*សម្តេចប្រធានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាវៀតណាម*

# សម្ដេចប្រធានព្រឹទ្ធសភាទទួលជួបប្រធានរដ្ឋសភាម៉ារ៉ុក





*ឯកឧត្តម Rachid Talbi EL Alami និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នាព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង៩:០០ នាទី នៅវិមានព្រឹទ្ធសភា សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបឯកឧត្តម Rachid Talbi EL Alami ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រម៉ារ៉ុក ក្នុងឱកាសដែលឯកឧត្តម Rachid Talbi EL Alami ដឹកនាំគណៈប្រតិភូអញ្ជើញមកចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមព្រឹទ្ធសភា និងខ្លួនសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការស្វាគមន៍ដ៏កក់ក្ដៅចំពោះឯកឧត្តមប្រធានរដ្ឋសភាម៉ារ៉ុក ដែលបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់មកចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣នាពេលនេះ។ ដំណើរទស្សនកិច្ច និងការចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ របស់គណៈប្រតិភូនៅពេលនេះ ពិតជាបានរួមចំណែកដល់ការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេស សភា និងប្រជាជននៃប្រទេសទាំងពីរ។

ក្នុងឱកាសនោះ ឯកឧត្តមប្រធានរដ្ឋសភាម៉ារ៉ុក បានសម្ដែងនូវការអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះសភាកម្ពុជាដែលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ហើយទទួលបានជោគជ័យ និងសមិទ្ធផលសំខាន់ៗ។

ឯកឧត្តមប្រធានរដ្ឋសភាម៉ារ៉ុកបានរំលឹកអំពីទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរដែលមានតាំងពីយូរលង់ណាស់មកហើយ ជាពិសេសប្រទេសម៉ារ៉ុកមានអារម្មណ៍ និងមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅដូចជាប្រទេសជិតខាងជាប់កម្ពុជា។

ឯកឧត្តមប្រធានរដ្ឋសភាម៉ារ៉ុកបានអះអាងថា ប្រទេសម៉ារ៉ុកតែងតែចាត់ទុកប្រទេសកម្ពុជា ជាតំណាងឱ្យប្រទេសម៉ារ៉ុកនៅអាស៊ីអាគ្នេយ៍ និងប្រទេសម៉ារ៉ុកជាតំណាងឱ្យ





*ទិដ្ឋភាពក្នុងពិធីជួបសម្ដែងការគួរសម*

ប្រទេសកម្ពុជានៅតំបន់អាហ្វ្រិក។

ឯកឧត្តមប្រធានរដ្ឋសភាម៉ារ៉ុកបានបញ្ជាក់ថា សភានៃប្រទេសទាំងពីរតែងតែគាំទ្រគ្នាទៅវិញទៅមកលើវាល់បញ្ហាពហុភាគី ទាំងក្នុងតំបន់ និងពិភពលោក។ នាពេលអនាគតឯកឧត្តមសង្ឃឹមថា ប្រទេសទាំងពីរនឹងខិតខំពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការបន្ថែមទៀត។ ក្នុងនោះប្រទេសទាំងពីរអាចបង្កើតឱ្យមានស្ថានតំណាងព្រះរាជាណាចក្រម៉ារ៉ុកប្រចាំព្រះរាជាណាចក្រកម្ពុជា និងស្ថានតំណាងព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រម៉ារ៉ុក។

សម្តេចប្រធានព្រឹទ្ធសភាបានរំលឹកថា ប្រទេសកម្ពុជា និងប្រទេសម៉ារ៉ុកបានបង្កើតទំនាក់ទំនងការទូតតាំងពីឆ្នាំ១៩៥៣។ ប្រទេសទាំងពីរមានប្រព័ន្ធនយោបាយប្រហាក់ប្រហែលគ្នា និងជាសមាជិក នៃអង្គការអន្តរជាតិនិយាយភាសាបារាំងដូចគ្នា។ ម៉ារ៉ុកគឺជាប្រទេសសង្កេតការណ៍យ៉ាងសកម្មរបស់អាយប៉ា។ ការអញ្ជើញចូលរួមមហាសន្និបាតរបស់គណៈប្រតិភូ បានបង្ហាញឱ្យឃើញច្បាស់ពីការគាំទ្រតួនាទីរបស់សភាកម្ពុជាជាប្រធានមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ក្រោមមូលបទ “បោះជំហានជាមួយគ្នា ដើម្បីចីរភាព បរិយាបន្ន និងភាពធន់របស់អាស៊ាន”។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវសេចក្តីរីករាយដោយមើលឃើញអំពីវឌ្ឍនភាពនៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដែលស្តែងឡើងតាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ច និងការគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការពហុភាគី។ ជាមួយគ្នានោះ សម្តេចបានសម្តែងនូវការគាំទ្រកិច្ចពិគ្រោះយោបល់លើកទី៣ រវាងក្រសួងការបរទេសទាំងពីរ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូនាពេលកន្លងទៅ ដោយស្នើឱ្យមានអនុស្សរណៈយោគយល់គ្នាស្តីពីការបង្កើតទីក្រុងសម្ព័ន្ធមេត្រីរវាងខេត្តសៀមរាប និងទីក្រុងកាសាប្លាំងកា (Casablanca) និងទីក្រុងម៉ារ៉ាកេច (Marrakech) និងកិច្ចព្រមព្រៀងស្តីពី ការការពារទៅវិញទៅមកនៃការវិនិយោគ។ ព្រឹទ្ធសភា និងខ្លួនសម្តេចផ្ទាល់សូមគាំទ្រ និងលើកទឹកចិត្តចំពោះកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល នៃប្រទេសទាំងពីរ និងសំណូមពរសូមអនុវត្តឱ្យអស់លទ្ធភាព ដើម្បីជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៃប្រទេសទាំងពីរ។

សម្តេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ព្រឹទ្ធសភាកម្ពុជាមានបំណងចង់ពង្រឹងពង្រីកទំនាក់ទំនង និងសហប្រតិបត្តិការរវាងសភាកម្ពុជា ជាមួយនឹងសភាម៉ារ៉ុក ជាពិសេសរវាងព្រឹទ្ធសភាកម្ពុជា ជាមួយព្រឹទ្ធសភាម៉ារ៉ុកឱ្យកាន់តែស៊ីជម្រៅ និងមានលទ្ធផលជាក់ស្តែងក្នុងពេលអនាគត តាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចគ្រប់កម្រិត បង្កើនកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានសភាទាំងពីរ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ការងារ និងការបណ្តុះបណ្តាលជំនាញសភា និងការជួយគាំទ្រគ្នាលើកិច្ចសហប្រតិបត្តិការអន្តរសភា ជាពិសេសក្របខ័ណ្ឌ IPU, AIPA, APF និងវេទិកាសភាតំបន់ និងអន្តរជាតិដទៃទៀត។

តាមរយៈគណៈប្រតិភូ សម្តេចប្រធានព្រឹទ្ធសភាសូមឯកឧត្តមប្រធានរដ្ឋសភាម៉ារ៉ុក មេត្តាជួយពាំនាំការផ្តាំផ្ញើសួរសុខទុក្ខដោយសេចក្តីគោរពរាប់អានជូនចំពោះឯកឧត្តមប្រធានព្រឹទ្ធសភាម៉ារ៉ុក និងសូមគោរពអញ្ជើញ ឯកឧត្តមប្រធានព្រឹទ្ធសភាម៉ារ៉ុកមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា នៅពេលវេលាសមស្របណាមួយ។

សម្តេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនគណៈប្រតិភូមានសុខភាពល្អ និងទទួលបានជោគជ័យ ព្រមទាំងទទួលបានផាសុកភាពក្នុងការស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្តេចប្រធានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយ ឯកឧត្តម Rachid Talbi EL Alami*

# សម្តេចប្រធានព្រឹទ្ធសភាទទួលជួបពិភាក្សាការងារជាមួយ លោកជំទាវប្រធានរដ្ឋសភាអាស៊ែបៃហ្សង់





*លោកជំទាវ Sahiba Gafarova និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ*

នាព្រឹកថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង៨:៣០ នាទី នៅវិមានព្រឹទ្ធសភា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបពិភាក្សាការងារជាមួយលោកជំទាវ Sahiba Gafarova ប្រធានរដ្ឋសភានៃសធារណរដ្ឋអាស៊ែបៃហ្សង់ ក្នុងឱកាសដែលលោកជំទាវប្រធានរដ្ឋសភាអាស៊ែបៃហ្សង់ ដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមមហាសន្និបាតអាយប៉ាលើកទី៤៣ នៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមព្រឹទ្ធសភា និងខ្លួនសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការស្វាគមន៍ដ៏កក់ក្តៅចំពោះលោកជំទាវប្រធានរដ្ឋសភា នៃសាធារណរដ្ឋអាស៊ែបៃហ្សង់ និងគណៈប្រតិភូ ដែលបានអញ្ជើញចូលរួមមហាសន្និបាតអាយប៉ាលើកទី៤៣នាពេលនេះ។ វត្តមានរបស់លោកជំទាវ និងគណៈប្រតិភូនាពេលនេះ ពិតជាបានរួមចំណែកដល់ការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេស សភា និងប្រជាជនទាំងពីរ។

ក្នុងឱកាសនោះ លោកជំទាវប្រធានរដ្ឋសភាអាស៊ែបៃហ្សង់ បានសម្តែងនូវការអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះសភាកម្ពុជា ដែលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ដោយទទួលបានជោគជ័យ និងសមិទ្ធផលសំខាន់ៗ។

លោកជំទាវប្រធានរដ្ឋសភាអាស៊ែបៃហ្សង់ បានបង្ហាញអំពីមនោសញ្ចេតនាដ៏ជ្រាលជ្រៅចំពោះប្រទេសកម្ពុជា បើទោះបីប្រទេសទាំងពីរមានភូមិសាស្ត្រខុសគ្នា និងឆ្ងាយ





*ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម*



ទិដ្ឋភាពក្នុងពិធីជួបសម្ដែងការគួរសម

ពីគ្នាក៏ដោយ ក៏ប្រទេសទាំងពីរហាក់ដូចជានៅជិតគ្នា។ លោកជំទាវបានរំលឹកអំពីទំនាក់ទំនងការទូត នៃប្រទេសទាំងពីរត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៤។ សាធារណរដ្ឋអាស៊ែបៃហ្សង់មាននិវេសនដ្ឋាននៅប្រទេសវៀតណាម ចំណែកឯព្រះរាជាណាចក្រកម្ពុជាមាននិវេសនដ្ឋាននៅទីក្រុងអង់ការ៉ា ប្រទេសតួកគី។ ស្ថានតំណាង នៃប្រទេសទាំងពីរតែងតែមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ។ ជាមួយគ្នានេះ ប្រទេសទាំងពីរក៏បានបង្កើតក្រុមមិត្តភាពរវាងសភា នៃប្រទេសទាំងពីរផងដែរ។ ទំនាក់ទំនងសភានៃប្រទេសទាំងពីរ ពិតជាបានដើរតួនាទីយ៉ាងសំខាន់។ ដូចនេះសភា នៃប្រទេសទាំងពីរគួរតែខិតខំបន្តការផ្លាស់ប្ដូរទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយគ្នាឱ្យកាន់តែរឹងមាំថែមទៀត។

លោកជំទាវប្រធានរដ្ឋសភាអាស៊ែបៃហ្សង់ បានជម្រាបជូនសម្ដេចប្រធានព្រឹទ្ធសភាជ្រាបថា ប្រទេសទាំងពីរមានឯកសារសំខាន់ចំនួន៣ កំពុងពិភាក្សា ហើយឯកសារចំនួន២ត្រូវបានចុះហត្ថលេខារួចហើយ។ សភា នៃប្រទេសទាំងពីរត្រូវតែមានទំនាក់ទំនងល្អជាមួយគ្នា ដើម្បីជួយដល់រដ្ឋាភិបាល នៃប្រទេសទាំងពីរក្នុងការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែរីកចម្រើនឡើងថែមទៀត។

លោកជំទាវប្រធានរដ្ឋសភាអាស៊ែបៃហ្សង់ បានថ្លែងអំណរគុណចំពោះសភាកម្ពុជា ដែលបានគាំទ្រសភាអាស៊ែបៃហ្សង់ជាអ្នកសង្កេតការណ៍ពេញសិទ្ធិ នៃមហាសន្និបាតអន្តរសភាអាស៊ាន។ ជាមួយគ្នានោះ លោកជំទាវបានគោរពអញ្ជើញសម្ដេចប្រធានព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋអាស៊ែបៃហ្សង់ក្នុងពេលវេលាសមស្របណាមួយ។

ក្នុងឱកាសនោះផងដែរ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការពេញចិត្តដោយមើលឃើញទំនាក់ទំនងរវាងប្រទេសទាំងពីរបន្តរីកចម្រើនជាបន្តបន្ទាប់។ ការរីកចម្រើននេះ ស្ដែងឡើងតាមរយៈការផ្លាស់ប្ដូរទស្សនកិច្ចទៅវិញទៅមករវាងមន្ត្រីជាន់ខ្ពស់ នៃប្រទេសទាំងពីរ សមាជិកសភាកម្ពុជាចូលរួមបណ្ដាញសភា នៃចលនាមិនចូលបក្សសម្ព័ន្ធជាពិសេសការអញ្ជើញបំពេញទស្សនកិច្ចនៅសាធារណរដ្ឋអាស៊ែបៃហ្សង់ជាផ្លូវការរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ២០១៤ កន្លងទៅ។

សម្ដេចប្រធាព្រឹទ្ធសភាបានបញ្ជាក់ថា ព្រឹទ្ធសភាសូមគាំទ្ររាល់កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល នៃប្រទេសទាំងពីរ និងសំណូមពរឱ្យបន្តពិភាក្សាគ្នា ដើម្បីបង្កើននូវកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗទៀត ដោយចាប់ផ្ដើមអនុវត្តឱ្យមានប្រសិទ្ធភាពចេញជាលទ្ធផលជាក់ស្ដែង ដើម្បី

ជាគុណប្រយោជន៍ក្នុងការអភិវឌ្ឍប្រទេសទាំងពីរប្រកបដោយវឌ្ឍនភាព។

សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណចំពោះសាធារណរដ្ឋអាស៊ែបៃហ្សង់ ដែលបានចាត់សមាជិកសភាចំនួន២រូប ចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ នៅកម្ពុជា។ អ្នកសង្កេតការណ៍អន្តរជាតិ រួមនឹងអ្នកសង្កេតការណ៍អាស៊ែបៃហ្សង់បានវាយតម្លៃខ្ពស់ អំពីបរិយាកាសបោះឆ្នោតនៅកម្ពុជាថា បានប្រព្រឹត្តទៅដោយសន្តិភាព គ្មានអំពើហិង្សា មានលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ។ ជាមួយគ្នានោះ សម្ដេចបានស្នើសុំអញ្ជើញតំណាងសភាអាស៊ែបៃហ្សង់ចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខនេះ។

សម្ដេចប្រធានព្រឹទ្ធសភាបានអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះតួនាទីរបស់លោកជំទាវជាប្រធានដឹកនាំសន្និសីទបណ្ដាញសភា នៃចលនាមិនចូលបក្សសម្ព័ន្ធ ប្រកបដោយជោគជ័យ និងសូមអបអរសាទរចំពោះលោកជំទាវ ដែលអង្គសន្និសីទបានបោះឆ្នោតជ្រើសតាំងជាប្រធានបណ្ដាញសភា នៃចលនាមិនចូលបក្សសម្ព័ន្ធ ក្នុងឱកាសសន្និសីទបណ្ដាញសភា នៃចលនាមិនចូលបក្សសម្ព័ន្ធកាលពីខែកក្កដា ឆ្នាំ២០២២ កន្លងទៅ នៅទីក្រុងបាគូ សាធារណរដ្ឋអាស៊ែបៃហ្សង់។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ព្រឹទ្ធសភាកម្ពុជាត្រៀមខ្លួនជានិច្ច ដើម្បីធ្វើកិច្ចសហប្រតិបត្តិការល្អជាមួយនឹងលោកជំទាវ ក៏ដូចជាសភាអាស៊ែបៃហ្សង់ ដើម្បីពង្រឹងពង្រីកទំនាក់ទំនងរវាងប្រទេស ប្រជាជន និងសភាទាំងពីរ ដោយខិតខំជំរុញឱ្យមានការផ្លាស់ប្ដូរទស្សនកិច្ចទៅវិញទៅមក និងជួយគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ នៃអន្តរសភា ជាអាទិ៍ក្នុងក្របខ័ណ្ឌបណ្ដាញសភា នៃចលនាមិនចូលបក្សសម្ព័ន្ធ សភាកម្ពុជាគាំទ្រ និងសហការពេញលេញជាមួយនឹងបណ្ដាញសភា នៃចលនាមិនចូលបក្សសម្ព័ន្ធ និងតាមរយៈក្របខ័ណ្ឌពហុភាគី នៃបណ្ដាញសភា នៃចលនាមិនចូលបក្សសម្ព័ន្ធជាមួយAIPA, IPU និងក្របខ័ណ្ឌផ្សេងទៀត។

ឆ្លើយតបនឹងការអញ្ជើញទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋអាស៊ែបៃហ្សង់ សម្ដេចប្រធានព្រឹទ្ធសភាបានទទួល និងជ្រើសរកពេលវេលាសមស្រប ដើម្បីទៅបំពេញទស្សនកិច្ច។ សម្ដេចបានប្រសិទ្ធពរជូនលោកជំទាវ និងគណៈប្រតិភូ មានសុខភាពល្អ និងទទួលបានជោគជ័យ ព្រមទាំងទទួលបានផាសុកភាពក្នុងការស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្ដេចប្រធានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយលោកជំទាវ Sahiba Gafarova និងគណៈប្រតិភូ*

# សម្ដេចប្រធានព្រឹទ្ធសភាទទួលជួបសវនាការជាមួយប្រធានរដ្ឋសភាឡាវ



*ឯកឧត្តម សៃស៊ុមផន ភូមវិហាន និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នាព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង១០:០០ នាទី នៅវិមានព្រឹទ្ធសភា សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបសវនាការជាមួយនឹងឯកឧត្ដម **សៃស៊ុមផន ភូមវិហាន** ប្រធានរដ្ឋសភា នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងឱកាសដែលឯកឧត្ដមដឹកនាំគណៈ-ប្រតិភូអញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ និងអញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមព្រឹទ្ធសភា និងខ្លួនសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការស្វាគមន៍ដ៏កក់ក្ដៅចំពោះឯកឧត្ដមប្រធានរដ្ឋសភាឡាវ ដែលបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ និងអញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។ នេះគឺជាការបង្ហាញអំពីការគាំទ្រតួនាទីរបស់សភាកម្ពុជាជាប្រធានអាយប៉ាលើកទី៤៣ និងធ្វើឱ្យមហាសន្និបាតអាយប៉ាលើកទី៤៣ ប្រព្រឹត្តទៅប្រកបដោយជោគជ័យ ក្រោមបរិយាកាសមិត្តភាព និងមជ្ឈភាពអាស៊ាន។ តាមរយៈដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនាឱកាសនេះ ពិតជាបានរួមចំណែកយ៉ាងខ្លាំងក្លាដល់ការពង្រឹងពង្រីកចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហ-ប្រតិបត្តិការរវាងប្រទេស និងប្រជាជនទាំងពីរ ដើម្បីជាគុណប្រយោជន៍រួមទាំងក្នុងពេលបច្ចុប្បន្ន និងពេលអនា-គត។

ក្នុងឱកាសនោះ ឯកឧត្ដមប្រធានរដ្ឋសភាឡាវ បានសម្ដែងនូវសេចក្ដីរីករាយដែលបានដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការលើកទី១ នៅព្រះ-រាជាណាចក្រកម្ពុជា ក្នុងនាមជាប្រធានរដ្ឋសភាឡាវ។ ឯកឧត្ដមបានសម្ដែងនូវការអបអរសាទរចំពោះប្រទេសកម្ពុជា ដែលបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ ព្រមទាំងរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ប្រកបដោយជោគជ័យ។ ជោគជ័យទាំងនេះបាននាំឱ្យកម្ពុជាមានមុខមាត់ក្នុងតំបន់ និងអន្តរ-ជាតិ ហើយក៏ជាមេរៀនដ៏ល្អ និងសំខាន់បំផុតចំពោះប្រទេសឡាវក្នុងការធ្វើម្ចាស់ផ្ទះរៀបចំមហាសន្និបាតអាយប៉ាលើកទី៤៥ នាឆ្នាំ២០២៤ ខាងមុខ។ ឯកឧត្ដមក៏បានអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានា និងការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា ជាពិសេសការទប់ស្កាត់ជំងឺកូវីដ-១៩ និងជោគជ័យ នៃការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២កន្លងទៅ។

ឯកឧត្ដមប្រធានរដ្ឋសភាឡាវបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងរដ្ឋាភិបាល និងសភា នៃប្រទេសទាំងពីរ។ ទំនាក់ទំនង





*ទិដ្ឋភាពក្នុងពិធីជួបសម្ដែងការគួរសម*

ទ្វេភាគីឡាវ-កម្ពុជា ត្រូវបានលើកកម្ពស់ជា “ដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង” និងមានការផ្លាស់ប្តូរគណៈប្រតិភូជាន់ខ្ពស់ទៅវិញទៅមក ព្រមទាំងមានការរីកចម្រើនជាលំដាប់ក្នុងការផ្លាស់ប្តូរវិស័យសេដ្ឋកិច្ច នយោបាយ ការបរទេស ការពារជាតិ ពាណិជ្ជកម្ម ដឹកជញ្ជូន អប់រំ និងទេសចរណ៍។ ប្រទេសទាំងពីរបានចាត់តាំងអនុវត្តនូវអនុសញ្ញា និងកិច្ចព្រមព្រៀងផ្សេងៗ ដើម្បីនាំយកនូវផលប្រយោជន៍រួមសម្រាប់ប្រទេសទាំងពីរ ហើយទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងសភា នៃប្រទេសទាំងពីរក៏មានទំនាក់ទំនងដ៏ល្អជាមួយគ្នា តាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ និងសមាជិកសភា នៃប្រទេសទាំងពីរ ជាពិសេសកិច្ចសហប្រតិបត្តិការរបស់ក្រុមមិត្តភាពទ្វេភាគី និងក្រុម CLV។ សភា នៃប្រទេសទាំងពីរបានគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌអន្តរសភា ជាពិសេស AIPA, APF, APPF, ASEP, IPU។ ឯកឧត្តមសង្ឃឹមថា ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងសភា នៃប្រទេសទាំងពីរ នឹងត្រូវបានពង្រឹងពង្រីកឱ្យកាន់តែរឹងមាំបន្ថែមទៀត។

ឯកឧត្តមប្រធានរដ្ឋសភាឡាវបានស្នើដល់សភានៃប្រទេសទាំងពីរពិចារណាចំនួន៤ចំណុចរួមមាន៖ ១.បន្តផ្លាស់ប្តូរដំណើរទស្សនកិច្ចថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីជំនាញ ២.ជំរុញរដ្ឋាភិបាលនៃប្រទេសទាំងពីរបន្តចាត់តាំងអនុវត្តកិច្ចព្រមព្រៀង និងគម្រោងនានា ឱ្យបានជោគជ័យ ដើម្បីជាប្រយោជន៍សម្រាប់ប្រទេសទាំងពីរ ៣.បន្តកិច្ចសហប្រតិបត្តិការ និងគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ៤.សូមគោរពអញ្ជើញសម្តេចប្រធានព្រឹទ្ធសភាទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នាពេលវេលាសមស្របណាមួយ។

ក្នុងឱកាសនោះដែរ សម្តេចប្រធានព្រឹទ្ធសភាបានគូសបញ្ជាក់ថា ប្រទេសទាំងពីរមានប្រពៃណីមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការតាំងពីយូរលង់ណាស់មកហើយ។ ថ្នាក់ដឹកនាំ នៃប្រទេសទាំងពីរគ្រប់ជំនាន់បានពូនជ្រំនូវចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំ និងស្រស់បំព្រង ដែលមិនអាចមានអ្នកណាមកជ្រៀតជ្រែក និងកម្លាំងអមិត្តណាមកបំបែកបំបាក់សាមគ្គីភាពរវាងប្រទេសទាំងពីរបានឡើយ។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការគាំទ្រ និង

លើកទឹកចិត្តឱ្យដល់រដ្ឋាភិបាល នៃប្រទេសទាំងពីរ ដើម្បីអនុវត្តនូវរាល់កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលជាក់ស្ដែង។ ជាមួយគ្នានោះ សម្ដេចបានអបអរសាទរចំពោះសភា នៃប្រទេសទាំងបី កម្ពុជា-ឡាវ-វៀតណាម ដែលបានសម្រេចដំឡើងកម្រិតនៃកិច្ចប្រជុំតំបន់ត្រីកោណអភិវឌ្ឍន៍ (CLV-DTA) ពីកម្រិតប្រធានគណៈកម្មការកិច្ចការបរទេស ទៅកម្រិតប្រធានសភា ដែលកិច្ចប្រជុំប្រព្រឹត្តទៅពីរឆ្នាំម្ដង ហើយប្រទេសឡាវនឹងធ្វើជាប្រធានកិច្ចប្រជុំនៅឆ្នាំ២០២៣ខាងមុខ។

សម្ដេចប្រធានព្រឹទ្ធសភាបានជម្រាបជូនឯកឧត្តមប្រធានរដ្ឋសភាឡាវជ្រាបថា ក្រោយវិបត្តិកូវីដ-១៩ ប្រទេសកម្ពុជាបានបើកប្រទេសឡើងវិញចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ និងបានបើកដំណើរការពេញលេញ សង្គម-សេដ្ឋកិច្ចតាមគន្លងប្រក្រតីភាពថ្មី។ យោងតាមការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី សេដ្ឋកិច្ចកម្ពុជា នឹងមានកំណើនក្នុងអត្រា ៥,៤% ក្នុងឆ្នាំ២០២២ និង ៦,៦% ក្នុងឆ្នាំ២០២៣។

សម្ដេចប្រធានព្រឹទ្ធសភាបានឯកភាពចំពោះការលើកឡើងរបស់ឯកឧត្តមប្រធានរដ្ឋសភាឡាវ ចំពោះការដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ ដើម្បីប្រែក្លាយព្រំដែនជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍលើគ្រប់វិស័យ ដើម្បីនាំមកនូវភាពសុខសាន្តជូនប្រទេសជាតិ និងប្រជាជន នៃប្រទេសទាំងពីរយូរអង្វែងជាមរតកសម្រាប់អ្នកជំនាន់ក្រោយ។ ជាមួយគ្នានោះ សម្ដេចបានឯកភាពក្នុងការជំរុញឱ្យរដ្ឋាភិបាល នៃប្រទេសទាំងពីរខិតខំអនុវត្តនូវកិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់គ្នាឱ្យចេញជាលទ្ធផលជាក់ស្ដែង ដើម្បីអភិវឌ្ឍប្រទេសប្រកបដោយវឌ្ឍនភាព។ ទន្ទឹមគ្នានោះ សម្ដេចបានឯកភាពចំពោះការពង្រឹងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ព្រមទាំងបង្កើនទំនាក់ទំនងក្នុងក្របខ័ណ្ឌ នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ហើយសម្ដេចក៏បានឯកភាពចំពោះសំណើទាំង៤ចំណុច។ សម្រាប់ការអញ្ជើញសម្ដេចទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សម្ដេចប្រធានព្រឹទ្ធសភាបានទទួលយក និងរកពេលវេលាសមស្រប ដើម្បីទៅបំពេញទស្សនកិច្ច។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ព្រឹទ្ធសភាកម្ពុជាត្រៀមខ្លួនជានិច្ច ដើម្បីធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយរដ្ឋសភាឡាវ ដើម្បីរួមចំណែកដល់ការពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ។

សម្ដេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនឯកឧត្តមប្រធានរដ្ឋសភា និងគណៈប្រតិភូឡាវ មានសុខភាពល្អបរិបូរណ៍ ទទួលបានជោគជ័យ និងរីករាយក្នុងពេលស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*ឯកឧត្តម សៃស៊ុមផន ភូមវិហាន ថតរូបអនុស្សាវរីយ៍ជាមួយ សម្ដេចប្រធានព្រឹទ្ធសភា*

# សម្តេចប្រធានព្រឹទ្ធសភាដឹកនាំគណៈប្រតិភូជាន់ខ្ពស់ ទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសវៀតណាម






*ឯកឧត្តម វឿង ឌិញហ្វេ និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ*

តបតាមការអញ្ជើញរបស់ឯកឧត្តម **វឿង ឌិញហ្វេ** ប្រធានរដ្ឋសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២។

ដំណើរទស្សនកិច្ចនោះ ធ្វើឡើងដើម្បីពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អ រវាងប្រជាជន និងប្រទេសទាំងពីរ ព្រមទាំងស្ថាប័ននីតិបញ្ញត្តិ នៃប្រទេសទាំងពីរ និងចូលរួមអបអរសាទរការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៥៥ឆ្នាំ ថ្ងៃបង្កើតទំនាក់ទំនងការទូត រវាងកម្ពុជា-វៀតណាម និងឆ្នាំមិត្តភាពកម្ពុជា-វៀតណាម។

ក្នុងឱកាសស្នាក់អាស្រ័យ និងបំពេញទស្សនកិច្ចនៅប្រទេសវៀតណាម សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលជួបសម្តែងការគួរសមជាមួយនឹង ឯកឧត្តម **ង្វៀន ហ្វ៊ូចុង** អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម និងឯកឧត្តម **ង្វៀន ស៊ួនហ្វ៊ុក** ប្រធានរដ្ឋវៀតណាម ព្រមទាំងបានជួបពិភាក្សាការងារទ្វេភាគីជាមួយនឹងឯកឧត្តម **វឿង ឌិញហ្វេ** ប្រធានរដ្ឋសភាវៀតណាម ឯកឧត្តម **ផាម មិញជីញ** នាយករដ្ឋមន្ត្រីវៀតណាម ឯកឧត្តម **ឌិញ ទៀនហ៊្សុង** លេខាគណៈកម្មាធិការបក្សទីក្រុងហាណូយ លោកជំទាវ **ង្វៀន ធីថាញ់** សមាជិកអចិន្ត្រៃយ៍រដ្ឋសភា និងជាប្រធានសមាគមមិត្តភាពវៀតណាម-កម្ពុជា និងលោកជំទាវ **ហា ធីយ៉ា** សមាជិការដ្ឋសភា និងជាប្រធានសហព័ន្ធនារីវៀតណាម។

តាមរយៈជំនួបសម្តែងការគួរសម និងជំនួបពិភាក្សាខាងលើនេះ គឺបានទទួលលទ្ធផលសំខាន់ៗមានជាអាទិ៍៖ សម្តេចប្រធានព្រឹទ្ធសភាបានពាំនាំនូវព្រះរាជបណ្តាំសួរសុខទុក្ខពីព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ និងពីថ្នាក់ដឹកនាំរដ្ឋសភា និង



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ និងឯកឧត្តម ង្វៀន ហ្វ៊ូចុង*



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ និងឯកឧត្តម ង្វៀន ស៊ួនហ្វ៊ុក*



ឯកឧត្តម ផាម មិញជីញ ស្វាគមន៍សម្តេចវិបុលសេនាភក្តី សាយ ឈុំ

រាជរដ្ឋាភិបាលកម្ពុជា ជូនថ្នាក់ដឹកនាំជាន់ខ្ពស់វៀតណាមទាំងអស់។ ជាមួយគ្នានោះ ថ្នាក់ដឹកនាំជាន់ខ្ពស់វៀតណាមក៏បានផ្តាំផ្ញើនូវការសួរសុខទុក្ខ និងថ្វាយព្រះពរ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ និងជូនពរថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាលកម្ពុជាវិញផងដែរ។

ថ្នាក់ដឹកនាំវៀតណាមបានវាយតម្លៃខ្ពស់ចំពោះព្រះរាជកិច្ចដឹកនាំប្រកបដោយព្រះរាជបញ្ញាញាណដ៏ឈ្លាសវៃរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ព្រមទាំងថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា ធ្វើឱ្យកម្ពុជាជម្នះបាននូវវិបត្តិ នៃជំងឺកូវីដ-១៩ និងមានការរីកចម្រើនផ្នែកសង្គម សេដ្ឋកិច្ច ដ៏ឆាប់រហ័ស មានសន្តិភាព ស្ថិរភាព កិត្យានុភាពក្នុងតំបន់ និងអន្តរជាតិ ព្រមទាំងបានប្រសិទ្ធពរឱ្យកម្ពុជាបន្តរីកចម្រើនកាន់តែរុងរឿងត្រចះត្រចង់ថែមទៀត។

ដោយឡែកក្នុងជំនួបពិភាក្សាជាមួយនឹងឯកឧត្តម **វឿង ឌិញហ្វេ** ប្រធានរដ្ឋសភាវៀតណាម ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកយ៉ាងទូលំទូលាយក្នុងបរិយាកាសស្និទ្ធស្នាល មិត្តភាព សាមគ្គីភាព ក្នុងស្មារតីជាអ្នកជិតខាងល្អ និងប្រកបដោយផ្លែផ្កា ដោយបានសម្តែងការពេញចិត្តយ៉ាងក្លៀវក្លាចំពោះការរៀបចំព្រឹត្តិការណ៍សំខាន់ៗជាច្រើនដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៥៥ឆ្នាំ ថ្ងៃបង្កើតទំនាក់ទំនងការទូត និងឆ្នាំមិត្តភាពកម្ពុជា-វៀតណាម ព្រមទាំងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដ៏ធំធេងលើគ្រប់វិស័យ និងគ្រប់កម្រិតដែលប្រទេសទាំងពីរសម្រេចបាននាពេលកន្លងមក និងបាននាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមកសម្រាប់ប្រជាជនទាំងពីរ។

សភាទាំងពីរបានសម្តែងការពេញចិត្ត និងវាយតម្លៃខ្ពស់បំផុតចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងព្រឹទ្ធសភាកម្ពុជា និងរដ្ឋសភាវៀតណាម ដែលស្តែងចេញតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចគ្រប់កម្រិតទៅវិញទៅមកជាញឹកញាប់ និងបន្តការគាំទ្រគ្នាទៅវិញទៅមកជាបន្តបន្ទាប់នៅក្នុងកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិនៃអន្តរសភា ដូចជា៖ IPU, AIPA, CLV-DTA, APPF, APF ASEP។

ភាគីទាំងពីរផ្តល់សារៈសំខាន់ដល់តួនាទីសភាក្នុងកិច្ចខិតខំប្រឹងប្រែងបន្តថែរក្សាពូនជ្រំនូវ ចំណងមិត្តភាព សាមគ្គីភាព និងសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យបានកាន់តែស៊ីជម្រៅ រឹងមាំ យូរអង្វែង ស្របតាមស្មារតី “ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ស្ថិរភាពយូរអង្វែង”។

សភាទាំងពីរបានឯកភាពគ្នាបន្តផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមកគ្រប់កម្រិត រួមមានថ្នាក់ដឹកនាំ គណៈកម្មការជំនាញ ដើម្បីផ្លាស់ប្តូរទស្សនៈ បទពិសោធន៍លើមុខងារសភាជាពិសេសការផ្លាស់ប្តូរសមាជិកសភាវ័យក្មេង សមាជិក-



សម្តេចវិបុលសេនាភក្តី សាយ ឈុំ និងឯកឧត្តម ឌិញ ទៀនហ៊ុង



សម្តេចវិបុលសេនាភក្តី សាយ ឈុំ និងលោកជំទាវ ង្វៀន ធីថាញ់

សភាជាស្ត្រី និងខិតខំលើកកម្ពស់ទំនាក់ទំនងការទូតសភា ដោយគាំទ្រគ្នាទៅវិញទៅមកលើវេទិកាអន្តរជាតិ ក្នុងគោលដៅរួមចំណែកដោះស្រាយបញ្ហាប្រឈមដ៏ស្រួចស្រាល់ នៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយនៅក្នុងតំបន់ និងអន្តរជាតិ។

សភាទាំងពីរបានឯកភាពចុះអនុស្សរណៈ នៃការយោគយល់គ្នាស្ដីពី កិច្ចសហប្រតិបត្តិការអន្តរសភារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា និងខុទ្ទកាល័យរដ្ឋសភាវៀតណាម ដែលគ្រោងធ្វើឡើងនៅខែវិច្ឆិកា ឆ្នាំ២០២២ ខាងមុខ។ រដ្ឋសភាវៀតណាមយល់ព្រមគាំទ្រផ្ដល់ជំនួយបច្ចេកទេស និងការអភិវឌ្ឍធនធានមនុស្សដល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា។

ក្នុងនាមសភាកម្ពុជា សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណចំពោះឯកឧត្តម **វឿង ឌិញហ្វេ** ប្រធានរដ្ឋសភាវៀតណាម ដែលបានគាំទ្រសភាកម្ពុជាជាប្រធានប្ដូរវេន នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (AIPA 43) និងអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការ ព្រមទាំងអញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នាខែវិច្ឆិកា ឆ្នាំ២០២២ នៅកម្ពុជា។

សភាទាំងពីរបានឯកភាពគ្នាបន្តការគាំទ្រ និងលើកទឹកចិត្តដល់រដ្ឋាភិបាលប្រទេសទាំងពីរអនុវត្តឱ្យបានពេញលេញនូវយន្តការដែលមានស្រាប់ និងអនុវត្តពេញលេញនូវរាល់កិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់គ្នាទៅវិញទៅមកនានា ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីនាំមកនូវវឌ្ឍនភាព និងវិបុលភាពរួម។

នៅក្នុងសភាពការណ៍បច្ចុប្បន្ន សម្ដេចប្រធានព្រឹទ្ធសភា និងថ្នាក់ដឹកនាំជាន់ខ្ពស់វៀតណាមបានសម្ដែងការពេញចិត្តជាខ្លាំងចំពោះចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ ក្រោមស្មារតីជា "អ្នកជិតខាងល្អ មិត្តភក្ដិល្អ បងប្អូនល្អ និងជាដៃគូល្អ"។ ទំនាក់ទំនងល្អនេះស្ដែងឡើងតាមរយៈការផ្លាស់ប្ដូរទស្សនកិច្ចទៅវិញទៅមករវាងថ្នាក់ដឹកនាំកំពូលៗ ថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានាជាញឹកញាប់ និងការគាំទ្រគ្នាទៅវិញទៅមកលើកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលបានរួមចំណែកយ៉ាងសំខាន់ដល់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់ និងអន្តរជាតិ។ ជាពិសេស ថ្នាក់ដឹកនាំវៀតណាមបានសម្ដែងការគាំទ្រតួនាទីកម្ពុជាជាប្រធានអាស៊ាន ដែលមានសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាស្នូល។

ជាមួយគ្នានោះ ភាគីទាំងពីរបានអបអរសាទរចំពោះទំនាក់ទំនងផ្នែកពាណិជ្ជកម្ម វិនិយោគ សេដ្ឋកិច្ច នយោបាយ សន្តិសុខ ការពារជាតិ វប្បធម៌ ការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ការបង្កើតផ្សារគំរូតាមព្រំដែន ដែលជួយសម្រួលដល់ការផ្លាស់ប្ដូរពាណិជ្ជកម្មតាមព្រំដែន ការផ្លាស់ប្ដូររវាងប្រជាជន និងប្រជាជន នៃប្រទេសទាំងពីរ និងបានរួមចំណែកដ៏សំខាន់ដល់ការលើកកម្ពស់កំណើនសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ ទប់ស្កាត់អតិផរណា និងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ច សន្តិសុខស្បៀង ដែលបណ្ដាលមកពីសង្គ្រាមនៅអ៊ុយក្រែន។

ភាគីទាំងពីរបានឯកភាពខិតខំជំរុញការតភ្ជាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធរវាងប្រទេសទាំងពីរ ប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ហើយខិតខំជំរុញការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែនឱ្យបានឆាប់។ ភាគីទាំងពីរបានសម្ដែងការអបអរសាទរចំពោះលទ្ធផលខណ្ឌសីមា និងបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ ដែលសម្រេចបាន៨៤% ហើយបន្តយកចិត្តទុកដាក់ខ្ពស់ដោះស្រាយការងារសេសសល់១៦% បន្ថែមទៀតឱ្យបានឆាប់ ដើម្បីប្រែក្លាយព្រំដែននៃប្រទេសទាំងពីរ ជាព្រំដែនសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ ប្រកបដោយចីរភាព ទាំងពេលបច្ចុប្បន្ន និងពេលអនាគត ដើម្បីទុកជាកេរមរតកសម្រាប់កូនចៅជំនាន់ក្រោយ។

ព្រមជាមួយគ្នានោះ សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណ បក្ស រដ្ឋ កងទ័ព និងប្រជាជនវៀតណាម ដែលបានជួយរំដោះកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ ប៉ុលពត ហើយជានិច្ចកាលវៀតណាមបានរួមចំណែកជួយគាំទ្រដល់ដំណើរការអភិវឌ្ឍ សង្គម សេដ្ឋកិច្ចកម្ពុជា លើគ្រប់វិស័យ ធ្វើឱ្យកម្ពុជាមានការរីកចម្រើនជាលំដាប់៕

(អត្ថបទ៖ ទេព មករា)



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ថតរូបអនុស្សាវរីយ៍ជាមួយលោកជំទាវ ហា ធីង៉ា*

# ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភាជួបពិភាក្សាការងារទ្វេភាគីជាមួយ អនុប្រធានក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន និងឯកឧត្តម Konstantin Kosachev*

នាព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង៩:០០នាទី ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបពិភាក្សាការងារទ្វេភាគី ជាមួយនឹងឯកឧត្តម Konstantin Kosachev អនុប្រធានក្រុមប្រឹក្សា-សហព័ន្ធ នៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី ក្នុងឱកាសដែល ឯកឧត្តម Konstantin Kosachev ដឹកនាំគណៈប្រតិភូអញ្ជើញ មកចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅ ព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានសម្ដែងនូវសេចក្ដី រីករាយ និងស្វាគមន៍យ៉ាងកក់ក្ដៅចំពោះឯកឧត្តម Konstantin Kosachev និងគណៈប្រតិភូ ដែលបានអញ្ជើញមកចូលរួមមហា-សន្និបាតអន្តរសភាអាស៊ានលើកទី៤៣ និងគាំទ្រតួនាទីរបស់ សភាកម្ពុជាជាប្រធានមហាសន្និបាតអន្តរសភាអាស៊ានលើកទី ៤៣ ធ្វើឱ្យមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ បាននឹង កំពុងប្រព្រឹត្តទៅក្រោមបរិយាកាសមិត្តភាព សហប្រតិបត្តិការ និងស្មារតីស្ថាបនា។ វត្តមានរបស់គណៈប្រតិភូនាពេលនេះ ពិត ជាបានរួមចំណែកដល់ការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហ-ប្រតិបត្តិការល្អ ដែលមានជាយូរលង់មកហើយ រវាងប្រទេស សភា និងប្រជាជនទាំងពីរ។

ក្នុងឱកាសនោះ ឯកឧត្តម Konstantin Kosachev បានសម្ដែង នូវសេចក្ដីរីករាយដែលបានអញ្ជើញមកចូលរួមមហាសន្និបាត អន្តរសភាអាស៊ានលើកទី៤៣ នៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងនាមជាអ្នកសង្កេតការណ៍នៃមហាសន្និបាតអន្តរសភាអាស៊ាន ប្រទេសរុស្ស៊ីតែងតែចូលរួមក្នុងព្រឹត្តិការណ៍នានារបស់អាយប៉ា ក្នុងនោះប្រទេសរុស្ស៊ីតែងតែយកចិត្តទុកដាក់ដល់ការអភិវឌ្ឍ ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសកម្ពុជា ក៏ដូចជាបណ្ដាប្រទេសក្នុងអាស៊ាន។ ជាមួយគ្នានោះ ឯកឧត្តមក៏ បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះប្រទេស កម្ពុជា ដែលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំមហាសន្និបាតអន្តរសភា អាស៊ានលើកទី៤៣ និងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ និងកិច្ចប្រជុំពាក់ព័ន្ធទទួលបានជោគជ័យ។

ឯកឧត្តម Konstantin Kosachev បានបញ្ជាក់ថា ប្រទេស រុស្ស៊ី និងប្រទេសកម្ពុជាមានទំនាក់ទំនងមិត្តភាព និងកិច្ចសហ-ប្រតិបត្តិការតាំងពីយូរលង់ណាស់មកហើយ។ ប្រទេសរុស្ស៊ី ចាត់ទុកប្រទេសកម្ពុជាជាដៃគូប្រកបដោយទុកចិត្ត។

ឯកឧត្តមបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានា និងការ អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមដ៏ឆាប់រហ័សរបស់ប្រទេសកម្ពុជា។ ឯកឧត្តមបានអះអាងថា ប្រទេសរុស្ស៊ីត្រៀមបញ្ជូនអ្នកសង្កេត-ការណ៍បោះឆ្នោតមកប្រទេសកម្ពុជានៅឆ្នាំ២០២៣។

ឯកឧត្តម Konstantin Kosachev បានស្នើដល់រដ្ឋាភិបាល និងសភា នៃប្រទេសទាំងពីរ ត្រូវយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំង ថែមទៀតដល់ការអភិវឌ្ឍទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ លើវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច និងការអភិវឌ្ឍធនធានមនុស្ស។ ក្រៅពីនេះ ប្រទេសទាំងពីរគួរតែអនុវត្តឱ្យកាន់តែស៊ីជម្រៅក្នុង ក្របខ័ណ្ឌគណៈកម្មការសេដ្ឋកិច្ច ពាណិជ្ជកម្ម វិជ្ជាជីវៈ និងបច្ចេក-





*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ជួបពិភាក្សាការងារទ្វេភាគីជាមួយអនុប្រធានក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី*

ទេស។ ក្នុងនោះ សូមឱ្យក្រុមការងារជាន់ខ្ពស់លើគម្រោងវិនិយោគអាទិភាព ចាប់ផ្ដើមការងារឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

ឯកឧត្តម Konstantin Kosachev បានស្នើសុំឱ្យក្រុមមិត្តភាពសភានៃប្រទេសទាំងពីរ បន្តពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ។ ក្នុងនោះ ក្រុមមិត្តភាព នៃប្រទេសទាំងពីរ អាចរៀបចំឱ្យមានកិច្ចប្រជុំរវាងប្រធានសភា នៃប្រទេសទាំងពីរ ទាំងនៅប្រទេសរុស្ស៊ី និងប្រទេសកម្ពុជា ហើយឯកឧត្តមបានស្នើបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធថែមទៀត រវាងអាយប៉ា ជាមួយនឹងសភា នៃបណ្ដារដ្ឋចំនួន៩ដែលជារដ្ឋអតីតសហភាពសូវៀត។

ក្នុងនាមរាជរដ្ឋាភិបាល សភា និងប្រជាជនកម្ពុជា ព្រមទាំងខ្លួនឯកឧត្តមផ្ទាល់ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអតីតសហភាពសូវៀតដែលបានជួយឧបត្ថម្ភគាំទ្រកម្ពុជាលើគ្រប់វិស័យ ក្នុងកាលៈទេសៈលំបាកបន្ទាប់ពីកម្ពុជារំដោះចេញពីរបបប្រល័យពូជសាសន៍ប៉ុល ពត និងត្រូវហ៊ុមព័ទ្ធខាងនយោបាយ និងសេដ្ឋកិច្ច។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលរុស្ស៊ីបានជួយបណ្ដុះបណ្ដាលធនធានមនុស្សរបស់កម្ពុជាដែលមាននិស្សិតជាង៨ពាន់នាក់បានរៀននៅសហភាពសូវៀត។ បច្ចុប្បន្ននេះ និស្សិតទាំងនោះកំពុងបម្រើការងារនៅតាមក្រសួង ស្ថាប័នរដ្ឋមួយចំនួន និងមានអតីតនិស្សិតមួយចំនួនកំពុងកាន់មុខដំណែងសំខាន់ៗនៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជា។ បច្ចុប្បន្នរុស្ស៊ីបន្តយកចិត្តទុកដាក់ជួយផ្ដល់អាហារូបករណ៍ដល់និស្សិតកម្ពុជាជាបន្តបន្ទាប់ ហើយឯកឧត្តមបានថ្លែងអំណរគុណចំពោះសភាសហព័ន្ធរុស្ស៊ីដែលបានជួយបណ្ដុះបណ្ដាលមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្នែកព័ត៌មានវិទ្យា និងផ្នែកទំនាក់ទំនងអន្តរជាតិ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានបញ្ជាក់ថា ព្រឹទ្ធសភាកម្ពុជាសូមគាំទ្រ និងលើកទឹកចិត្តដល់រដ្ឋាភិបាលនៃប្រទេសទាំងពីរអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវកិច្ចព្រមព្រៀងអនុស្សរណៈយោគយល់ ដែលរដ្ឋាភិបាល នៃប្រទេសទាំងពីរ បានសម្រេចរួមគ្នានាពេលកន្លងទៅ ដែលឈរលើមូលដ្ឋានច្បាប់ជាតិ និងច្បាប់អន្តរជាតិ ហើយផ្ដល់ផលប្រយោជន៍ទៅវិញទៅមកសម្រាប់ប្រជាជន និងប្រទេសទាំងពីរ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានកត់សម្គាល់ឃើញថា នាពេលបច្ចុប្បន្ននេះ ការទូតសភាកាន់តែមានសារៈសំខាន់ខ្លាំងឡើង និងសកម្មក្នុងកិច្ចសហប្រតិបត្តិការពហុភាគីនិយម ដើម្បីរួមចំណែកដោះស្រាយបញ្ហាប្រែប្រួល ស្មុគស្មាញដ៏ឆាប់រហ័ស និងគ្រោះថ្នាក់ ពិបាកប៉ាន់ស្មាន នៃការប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយ ដែលបង្កឱ្យមានសង្គ្រាមនៅតាមតំបន់នានា អសន្តិសុខ វិបត្តិស្បៀង ថាមពល និងបញ្ហាបរិស្ថាន។ សកម្មភាពឆ្លើយតបត្រូវធ្វើរួមគ្នាដោយបុរេសកម្ម និងជាក់ស្តែងដោយស្មារតីគោរពផលប្រយោជន៍ អធិបតេយ្យភាព ឯករាជ្យភាពទៅវិញទៅមក និងគោរពនូវគុណតម្លៃច្បាប់អន្តរជាតិ ឈានទៅកសាងតំបន់ និងពិភពលោក ប្រកបដោយសន្តិភាព ស្ថិរភាព វិបុលភាព និងការអភិវឌ្ឍយូរអង្វែងសម្រាប់កូនចៅយើងជំនាន់បច្ចុប្បន្ន  និងជំនាន់ក្រោយ។

ចំពោះបញ្ហានៅអ៊ុយក្រែន ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានបញ្ជាក់ថា កម្ពុជាផ្ដល់សារៈសំខាន់ដល់ការចរចា និងជំរុញឱ្យមានដំណោះស្រាយដោយសន្តិវិធី ពីព្រោះសង្គ្រាមពុំមែនជាដំណោះស្រាយនៃវិបត្តិទេ។ កម្ពុជាបានធ្លាក់ទៅក្នុងភ្លើងសង្គ្រាមជាបន្តបន្ទាប់ចាប់តាំងពីចុងទសវត្សរ៍៦០ ហើយបានប្រយុទ្ធគ្នាអស់ជាច្រើនឆ្នាំ ប៉ុន្តែមិនអាចរកឃើញជ័យជម្នះ និងសន្តិភាពជាស្ថាពរបានទេ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានប្រសិទ្ធពរជូនគណៈប្រតិភូ សូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងដំណើរបេសកកម្មដ៏ឧត្តុង្គឧត្តមនៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គឹម សិទ្ធី)



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម Konstantin Kosachev*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១២:០០ នាទី គណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានអញ្ជើញធ្វើមាតុភូមិនិវត្តន៍មកកាន់មាតុប្រទេសវិញប្រកបដោយសុវត្ថិភាព បន្ទាប់ពីអញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០២២។



❈នារាត្រីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងសមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងព្រះរាជកម្មវិធី “១០០ ព្រះវស្សានៃព្រះបិតាឯករាជ្យជាតិ” នៅសាលមហោស្រពចតុមុខមង្គល។




❈នាព្រឹកថ្ងៃពុធ ទី៩ ខែវិច្ឆិកា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងឯកឧត្ដមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញសួរសុខទុក្ខលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា នៅភូមិតាព្រហ្ម សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។



❈នាថ្ងៃត្រង់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជនាហារផ្លូវរដ្ឋជាផ្លូវការ ថ្វាយព្រះចៅស៊ុលតង់ **ហាជី ហាសសាណាល់ បុលគីយ៉ាស់ មុយអ៊ីហ្សាឌីន វ៉ាឌូឡាហ៍** (Sultan Haji Hassanal Bolkiah Mu’izzaddin Waddaulah) ព្រះមហាក្សត្រ និងជាព្រះប្រមុខរដ្ឋនៃប្រទេសព្រុយណេដារូសាឡឹម នៅព្រះបរមរាជវាំង។



## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នារាត្រីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានរៀបចំពិធីដាល់អំបុក អកអំបុក និងបណ្តែតប្រទីប ដើម្បីអបអរសាទរ ព្រះរាជពិធីបុណ្យ អុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅសង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល។



❈នារសៀលថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធបុព្វការីជន នៅវិមានឯករាជ្យ រាជធានីភ្នំពេញ ក្នុងឱកាសទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើត នៃកងយោធពលខេមរភូមិន្ទ។



❈នារសៀលថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញថ្វាយកម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា ព្រះបាទសម្តេចព្រះ**នរោត្តមសីហនុ**ព្រះបរមរតនកោដ្ឋ នៅព្រះមណ្ឌបតម្កល់ព្រះបរមរូប ជិតវិមានឯករាជ្យ រាជធានីភ្នំពេញ ក្នុងឱកាសទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ។



❈នារាត្រីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមពិធីលៀងសាយភោជន៍ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភាបណ្តាប្រទេសសមាជិកអាយប៉ា និងប្រទេសអ្នកសង្កេតការណ៍ ភ្ញៀវជាតិ និងអន្តរជាតិ នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ៕



# គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយក្រសួងព័ត៌មាន




*គណៈកម្មការទី៥ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រសួងព័ត៌មាន*

នាព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) ដឹកនាំដោយឯកឧត្តម **ឈិត គឹមយាត** ប្រធានស្តីទីគណៈកម្មការ បានទទួលជួបពិភាក្សាការងារជាមួយនឹងក្រសួងព័ត៌មាន ដឹកនាំដោយឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តម **ឈិត គឹមយាត** បានបញ្ជាក់ជូនអង្គប្រជុំបានជ្រាបអំពីគោលបំណង នៃជំនួបពិភាក្សាដើម្បីឈ្វេងយល់អំពី៖ ១.លទ្ធផលការងារសម្រេចបានរបស់ក្រសួងក្នុងឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត ២.វិធានការ នៃការគ្រប់គ្រងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ អ្នកយកព័ត៌មានតាមបណ្តាញសង្គម (Facebook) ដែលកំពុងមានសកម្មភាពក្នុងពេលបច្ចុប្បន្ន ៣.ដំណើរការកសាងសេចក្តីព្រាងច្បាប់ស្តីពី សិទ្ធិទទួលព័ត៌មាន និងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងវិស័យព័ត៌មាន។ ជាមួយគ្នានោះគណៈកម្មការក៏បានលើកឡើងនូវសំណួរមួយចំនួនពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ក្រសួងព័ត៌មាន ចំពោះការផ្លាស់ប្តូរប្រព័ន្ធផ្សព្វផ្សាយពីប្រព័ន្ធអ៊ិនណាឡូមកប្រព័ន្ធឌីជីថល និងវិធានការរបស់ក្រសួង ចំពោះអ្នកសារព័ត៌មាន ដែលពុំបានឆ្លងកាត់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាន និងអ្នកសារព័ត៌មានមួយចំនួនតូច ដែលបានប្រើប្រាស់សេរីភាពហួសដែនកំណត់។

ជាការឆ្លើយតប ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានជម្រាបជូនគណៈកម្មការទី៥ព្រឹទ្ធសភាជ្រាបអំពីដំណើរការរួមដែលក្រសួងបានខិតខំបំពេញ និងលទ្ធផលការងារសម្រេចបានរបស់ក្រសួងក្នុងឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត ជាពិសេសវិស័យព័ត៌មាន និងសោតទស្សន៍។ ចំពោះការផ្លាស់ប្តូរប្រព័ន្ធផ្សព្វផ្សាយពីប្រព័ន្ធអ៊ិនណាឡូមកប្រព័ន្ធឌីជីថល គឺជួយឱ្យការផ្សព្វផ្សាយមានភាពច្បាស់ល្អ ហើយនៅលើពិភពលោកក៏ឈប់ផលិតទូរទស្សន៍ អ៊ិនណាឡូមទៀតដែរ។ ចំពោះអ្នកសារព័ត៌មានដែលពុំបានឆ្លងកាត់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាន ក្រសួងនឹងបើកវគ្គបណ្តុះបណ្តាលជាបន្តទៀត។ ដោយឡែកអ្នកសារព័ត៌មានមួយចំនួនតូច ដែលបានប្រើប្រាស់សេរីភាពហួសដែនកំណត់ នៅពេលដែលអ្នកសារព័ត៌មានណាម្នាក់បានធ្វើខុសជាមួយនឹងភាគីណាមួយ គឺត្រូវធ្វើការកែតម្រូវឡើងវិញ ក្នុងករណីមិនកែតម្រូវ ភាគីដែលមានវិវាទមានសិទ្ធិប្តឹងដោយផ្អែកលើច្បាប់ស្តីពី សិទ្ធិទទួលព័ត៌មាន។

បន្ទាប់ពីបានស្តាប់ការបំភ្លឺរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មានរួចមក ឯកឧត្តម **ឈិត គឹមយាត** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំគ្រប់ថ្នាក់ គ្រប់ផ្នែក នៃក្រសួងព័ត៌មាន ដែលបានខិតខំបំពេញការងារឱ្យមានការរីកចម្រើនល្អឈានឡើង និងសម្រេចបានលទ្ធផលយ៉ាងល្អប្រសើរ។ ក្រៅពីនេះក្រសួងក៏បានខិតខំអនុវត្តតួនាទី ភារកិច្ច និងការគ្រប់គ្រងកាសែត វិទ្យុ ទូរទស្សន៍ សារព័ត៌មានផ្សេងៗ និងដោះស្រាយបញ្ហាផ្សព្វផ្សាយបានល្អប្រសើរ៕

(អត្ថបទ៖ ធុន គីមជី រូបភាព៖ គឹម សិទ្ធី)

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ចុះសួរសុខទុក្ខ និងនាំយកអំណោយជូនប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន២៣៤គ្រួសារ នៅស្រុកត្បូងឃ្មុំ



ឯកឧត្តម អ៊ុក ប៊ុនឈឿន ចុះសួរសុខទុក្ខប្រជាពលរដ្ឋដែលរងគ្រោះទឹកជំនន់

នាថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដឹកនាំដោយឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុម បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយរបស់ស្ថានទូតកូរ៉េប្រចាំកម្ពុជា តាមរយៈសមាគមប្រភពល្អកម្ពុជា ចែកជូនប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់ចំនួន២៣៤គ្រួសារ មកពីភូមិជីរោទ៍ទី១ និងភូមិជីរោទ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ ពិធីនេះប្រព្រឹត្តទៅនៅវត្តរកាធំ ស្ថិតក្នុងភូមិជីរោទ៍ទី១ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានសម្តែងនូវការសោកស្តាយជាមួយនឹងបងប្អូនប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់ ធ្វើឱ្យខូតខាតដំណាំ ស្រែចម្ការ។ ដោយមើលឃើញពីផលលំបាកទាំងអស់នោះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បាននាំយកអំណោយមកចែកជូនបងប្អូនប្រជាពលរដ្ឋ។ ថ្វីត្បិតតែអំណោយទាំងនោះមានតិចតួចក្តី ប៉ុន្តែអាចផ្គត់ផ្គង់ និងជួយសម្រួលដល់ការលំបាក ការខ្វះខាតរបស់បងប្អូនប្រជាពលរដ្ឋបានមួយរយៈដែរ។

ជាមួយគ្នានោះ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានផ្តាំផ្ញើឱ្យបងប្អូនប្រជាពលរដ្ឋយកចិត្តទុកដាក់ និងខិតខំបង្កបង្កើនផល ដាំដំណាំគ្រប់ប្រភេទ បន្ទាប់ពីទឹកបានស្រកទៅវិញ ដើម្បីបង្កើនជីវភាពប្រចាំថ្ងៃរបស់បងប្អូន។ ក្រៅពីនេះត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយនៅក្នុងភូមិ ឃុំ គោរពច្បាប់ កុំប្រព្រឹត្តអំពើពុករលួយ ឆក់ ប្លន់ និងអំពើមិនល្អផ្សេងៗ។ ឯកឧត្តមក៏បានផ្តាំផ្ញើឱ្យបងប្អូនប្រជាពលរដ្ឋយកចិត្តទុកដាក់អប់រំណែនាំដល់កូនចៅឱ្យប្រព្រឹត្តអំពើល្អ ការពារភូមិ ឃុំ របស់ខ្លួនឱ្យកាន់តែល្អប្រពៃតទៅទៀត ព្រមទាំងចូលរួមថែរក្សាអនាម័យទាំងអស់គ្នា។

ក្នុងឱកាសនោះផងដែរ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានថ្លែងអំណរគុណដល់ស្ថានទូតកូរ៉េប្រចាំកម្ពុជា ដែលបានផ្តល់អំណោយ តាមរយៈសមាគមប្រភពល្អកម្ពុជា យកមកផ្តល់ជូនប្រជាពលរដ្ឋនាពេលនោះ។

អំណោយទាំងនោះបានយកទៅចែកជូនប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់ និងរងផលប៉ះពាល់ខូចដំណាំប្រជាពលរដ្ឋចំនួន២៣៤គ្រួសារ ដោយក្នុងមួយគ្រួសារៗទទួលបាន អង្ករ២៥គីឡូក្រាម មី១កេស និងទឹកត្រី១យួរ។៚

(អត្ថបទ៖ គឹម សិទ្ធី រូបភាព៖ ធុន គីមជី)



ទិដ្ឋភាពក្នុងពិធីសំណេះសំណាល និងចែកអំណោយ

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❈ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖



-ដឹកនាំកិច្ចប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំកិច្ចប្រជុំជាមួយនឹងក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ និងពិនិត្យលើសំណើរបស់តំណាងសហគមន៍ជនជាតិដើមភាគតិច ១៦អំបូរជនជាតិ ក្នុងការកែសម្រួលសេចក្ដីព្រាងច្បាប់ស្ដីពី តំបន់ការពារធម្មជាតិ និងសេចក្ដីព្រាងច្បាប់ស្ដីពី ព្រៃឈើ នាព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

-ជួបប្រជុំពិភាក្សាជាមួយឯកឧត្តម **សរ ចំរុង** ប្រធានគណៈ-កម្មការទី១រដ្ឋសភា ដើម្បីត្រៀមរៀបចំពិធីអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី៧៤ នាព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលប្រជុំពិសេស៣ព្រឹទ្ធសភា។

❈នាថ្ងៃទី១៨ និងថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ឌឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមរៀបចំខ្លឹមសារ និងឯកសារពាក់ព័ន្ធនានា ដើម្បីទទួលគណៈប្រតិភូបេសកកម្មសុឆន្ទៈ នៃសភាប្រើប្រាស់ភាសាបារាំង ដែលគ្រោងមកទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំកិច្ចប្រជុំពិនិត្យលើការងារសំខាន់ៗរបស់គណៈកម្មការទី៨ព្រឹទ្ធសភា និងទិសដៅការងារនៅក្នុងចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤ នាព្រឹកថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។



-ដឹកនាំកិច្ចប្រជុំគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជានៃព្រឹទ្ធសភា នៅសាលពិសេស វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំ៖



-គណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចរបាយ-ការណ៍ស្ដីពី សកម្មភាព និងលទ្ធផលការងារ និងរបាយការណ៍ថវិការបស់គណៈកម្មការទី១០ព្រឹទ្ធសភាប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ នារសៀលថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលប្រជុំគណៈ-កម្មការទី១០ព្រឹទ្ធសភា។



-មន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី១០ព្រឹទ្ធសភា និងមន្ត្រីលេខាធិការដ្ឋានអមអ្នកនាំពាក្យព្រឹទ្ធសភា ដើម្បីពិនិត្យអំពីវឌ្ឍនភាពការងារ និងលើកទិសដៅបន្ត នារសៀលថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។



❈នាថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុង

កិច្ចប្រជុំជាមួយនឹងតំណាងអង្គការការីតាស និងមន្ត្រីដែលពាក់ព័ន្ធ ស្តីពីការរៀបចំពិធីអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី៧៤ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

❈ឯកឧត្តម **ឈិត គឹមយាត** ប្រធានស្តីទីគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំ៖



-គណៈកម្មការទី៥ព្រឹទ្ធសភា ដើម្បីពិនិត្យ និងសម្រេចលើកចុងក្រោយផែនការប្រតិបត្តិរបស់គណៈកម្មការទី៥ព្រឹទ្ធសភាឆ្នាំ២០២៣ និងពិនិត្យកម្រងសំណួរ ជំនួយស្មារតី និងសំណូមពរនានាមុនជួបពិភាក្សាការងារជាមួយនឹងក្រសួងព័ត៌មាន នាព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា។

-ត្រៀមរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាង សេចក្តីសម្រេចរបស់គណៈកម្មាធិការរៀបចំនៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ដែលសភា នៃព្រះរាជាណាចក្រកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ចាប់ពីថ្ងៃទី



២០ ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ នាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ លោកជំទាវ **ម៉ុំ សណ្ណាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យកែសម្រួលលើរបាយការណ៍សង្ខេបស្តីពីលទ្ធផល នៃការចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក លើកទី៣០ (APPF-30th) នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស




❈នាថ្ងៃទី២៦ ដល់២៩ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ម៉ុំ សណ្ណាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិកលើកទី៣០ (APPF-30) ក្រោមមូលបទ "សភា និងការអភិវឌ្ឍប្រកបដោយចីរភាពក្រោយជំងឺកូវីដ-១៩" នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍។

❈នាថ្ងៃទី១ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម



កិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និងឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំការងារសើរើលក្ខន្តិកៈសភាប្រើភាសាបារាំង (APF) មហាសន្និបាតប្រចាំឆ្នាំ នៃបណ្តាញក្រុមសីលធម៌សមាជិកសភា (APF) នៅសាធារណរដ្ឋបារាំង ពីថ្ងៃទី៣ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២២ និងទស្សនកិច្ចការងារនៅសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល-ប៊ែលហ្សិក ពីថ្ងៃទី៩ ដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០២២៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❋នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះ-សំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ ព្រមទាំងឧបត្ថម្ភអំពូលភ្លើងដើរដោយពន្លឺព្រះអាទិត្យចំនួន១គ្រឿងសម្រាប់បំភ្លឺនៅសាលាសង្កាត់កណ្តាល ខេត្តក្រចេះ។



❋នាថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់បឹងធំ ស្មៀន និងប្រធានការិយាល័យចុះឈ្មោះបោះឆ្នោត ស្តីពីយុទ្ធនាការចុះឈ្មោះបោះឆ្នោត និងសភាពការណ៍ទូទៅនៅក្នុងមូលដ្ឋាន នៅសាលាសង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធ-សភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋដែលអញ្ជើញមកទស្សនាសួនសត្វ ព្រមទាំងដឹកនាំក្រុមការងារគ្រឿង-ចក្រសាងសង់សហចេតិយ រោងបុណ្យ និងកែលម្អសួនសត្វឱ្យមានសោភណ្ឌភាព ព្រមទាំងផាសុកភាពសត្វប្រសើរឡើងវិញ ដើម្បីទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិចូលទស្សនាកម្សាន្តនៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមការងារគ្រឿង-ចក្រកំពុងសាងសង់ទំនប់ទឹកថ្មីបន្ថែមទៀត ដែលមានបណ្តោយ ៣៥០x១៥០ម៉ែត្រ ដើម្បីស្តាក់ទឹកទុកប្រើប្រាស់ ព្រមទាំងបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខក្រុមការងារគ្រឿងចក្រឈូសឆាយសម្អាតបើកការដ្ឋានសាងសង់ផ្លូវឡើងភ្នំបូកគោ និងក្រុមការងារកំពុងសាងសង់ផ្លូវល្បឿនលឿននៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋកំពុងសម្រាកកម្សាន្ត និងទស្សនាសួនសត្វនៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៧ ទី១១ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋកំពុងនេសាទត្រី នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខ និងណែនាំកម្មករអំពីរបៀបថែទាំដំណាំផ្សេងៗ និងចុះពិនិត្យមើលទំនប់ទឹក និងហេដ្ឋា-រចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលទំនប់ទឹកទំហំ៣០០ម៉ែត្រX១២០ម៉ែត្រ ដែលកំពុងសាងសង់ជិតរួចរាល់ជាស្ថាពរ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មកររោងចក្រផលិតចំណីសត្វ និងផលិតកៅស៊ូក្រែប ព្រមទាំងចុះពិនិត្យការងារសាង-សង់ផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ៤ ឆ្ពោះទៅកាន់ជើងភ្នំបូកគោ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលថ្នាលបណ្តុះកូនឈើព្រៃ និងកូនដើមក្រូចថ្លុងសរុបចំនួន៥០.០០០ដើម ដើម្បីត្រៀមទុកសម្រាប់ដាំនៅដើមរដូវវស្សាឆ្នាំ២០២៣ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២។



❋នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះ-សំណាលជាមួយនឹងអាជ្ញាធរឃុំបុសមន លោកគ្រូ អ្នកគ្រូ និងពិនិត្យទីតាំងសាងសង់អគារសិក្សាថ្មីជូនបឋមសិក្សាហ៊ុនសែន-បុសមនលើ នៅក្នុងឃុំបុសមន ស្រុករំដួល ខេត្តស្វាយរៀង។

❋នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងឯកឧត្តម **ឈួន ឡេង**

អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូននិស្សិតជ័យលាភី សាកលវិទ្យាល័យជាតិ ជា ស៊ីម កំចាយមារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកកំចាយមារ ខេត្តព្រៃវែង។

❈នាថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សា ឃុំ និងប្រជាពលរដ្ឋ ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។



❈នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សា និងមន្ត្រីការិយាល័យចុះឈ្មោះបោះឆ្នោត នៅសាលាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន និងដំណើរការពិនិត្យបញ្ជីឈ្មោះ ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន។

❈ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន និងដំណើរការពិនិត្យបញ្ជីឈ្មោះ ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នាថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២។



-ពិសាអាហារសាមគ្គី និងសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ស្នោរ សង្កាត់ឱឡោក និងគណៈគ្រប់គ្រងសាលា នៅអាហារដ្ឋានក្នុងសង្កាត់ស្នោរ រាជធានីភ្នំពេញ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។

❈នារសៀលថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។



❈នាព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភានិងឯកឧត្តម **ញ៉ែប សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល និងពិធីចែកស្រូវពូជជូនប្រជាពលរដ្ឋចំនួន៥.១៤៥គ្រួសារ ដែលរងគ្រោះដោយសារគ្រោះទឹកជំនន់ នៅខេត្តពោធិ៍សាត់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានខេត្តពោធិ៍សាត់។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាកិត្តិយសក្នុងពិធីសម្ពោធសាលប្រជុំរំដួល ក្រោមអធិបតីភាពឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសាលាខេត្តកណ្តាល នាព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២។

-នាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនដល់មណ្ឌលកុមារកំព្រា ព្រមទាំងនាំយកថ្នាំពេទ្យមួយចំនួនធំទៅប្រគល់ជូនមន្ទីរ-



ពេទ្យបង្អែកខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២២។

❈នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបុណ្យសពលោក **ស៊ុន យឹម** មេឃុំព្រែកសំបួរ នៅស្រុកពាមជរ ខេត្តព្រៃវែង។

❈នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ម៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះ-សំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំទាំងអស់ នៃស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធ-សភាបានអញ្ជើញ៖



-ចូលរួមជាគណៈអធិបតីភាពក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ ដើម្បីស្តាប់របាយការណ៍ស្តីពី វឌ្ឍនភាពការងារវិនិយោគ៣ឆ្នាំរំកិល រាជធានីភ្នំពេញ និងសកម្មភាពជាអាទិភាពរបស់ក្រុមប្រឹក្សារាជ-ធានីភ្នំពេញ ព្រមទាំងទទួលដោះស្រាយសំណូមពរ ជូនបងប្អូនប្រជាពលរដ្ឋលើការងារសន្តិសុខ សណ្តាប់ធ្នាប់ ចរាចរណ៍ បង្រ្កាបទីតាំងល្បែងស៊ីសង និងកុងស៊ីបញ្ជាំខុសច្បាប់ ការពារសន្តិសុខ សុវត្ថិភាពសាធារណៈសម្រាប់កិច្ចប្រជុំកំពូលASEAN, AIPA នៅមហោស្រពចេនឡា ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២។

-ចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ គណៈ-បញ្ជាការឯកភាព និងមេភូមិទាំង១៣ ខណ្ឌទួលគោក រាជធានី-ភ្នំពេញ ដើម្បីពិនិត្យលទ្ធផលការងារខែតុលា និងលើកទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២២ ដើម្បីការពារសន្តិសុខ សុវត្ថិភាពតាមគោលដៅសំខាន់ៗក្នុងភូមិសាស្ត្រខ្លួន សម្រាប់កិច្ចប្រជុំកំពូល



ASEAN, AIPA និងបន្តបង្កលក្ខណៈសម្បត្តិងាយស្រួលជូនបងប្អូនប្រជាពលរដ្ឋ ដែលដល់អាយុបោះឆ្នោតស្របតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងឧបត្ថម្ភកង់ ចំនួន២គ្រឿង ជូនមន្ត្រីខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា នាថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចូលរួមពិធីសូត្រមន្តបុណ្យអង្គកឋិនសាមគ្គី ដើម្បីដង្ហែទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាសក្នុងពុទ្ធសីមានៅវត្តនាគវ័ន រាជធានីភ្នំពេញ និងវត្តវិហារ ខេត្តកណ្តាល នាថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចូលរួមជាមួយនឹងប្រធានក្រុមប្រឹក្សាសង្កាត់ លោកនាយកវិទ្យាល័យសន្ធរម៉ុក ស្ថិតនៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីឈ្វេងយល់អំពីការរៀបចំបន្ទប់ត្រៀមប្រឡងទុតិយភូមិ នាខែធ្នូ ឆ្នាំ២០២២ ខាងមុខ និងឧបត្ថម្ភថវិកាមួយចំនួន នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចូលរួមជាមួយក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ចុះពិនិត្យជាក់ស្ដែងការប្រើប្រាស់កញ្ចប់ថវិកាអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីចាក់ក្រាលកៅស៊ូ Asphalt ប្រវែង៣៨៧ម៉ែត្រ លើបណ្ដោយផ្លូវលេខ១៥០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២។

❋ឯកឧត្ដម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖



-នាំយកអំណោយឧបត្ថម្ភដល់ក្រុមកីឡាករប្រណាំងទូក រួមមាន៖ អង្ករចំនួន១០០គីឡូក្រាម ស្រាបៀរចំនួន៥កេស ក្រមាចំនួន២៥ ថវិកាមួយចំនួន នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងមន្ត្រីពាក់ព័ន្ធ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនរដ្ឋបាលឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២។

❋ឯកឧត្ដម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពលោក **ញឹក អ៊ុច** សមាជិកក្រុមប្រឹក្សាសង្កាត់សុព័រទេព នៅភូមិរលាំងសង្កែ សង្កាត់សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីប្រណាំងទូក នៅខេត្តកំពង់ស្ពឺ ពីថ្ងៃទី៧ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២២ និងបានឧបត្ថម្ភថវិកាមួយចំនួនដល់គណៈរៀបចំអង្គពិធី នាព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាលនឹងសួរសុខទុក្ខលោកជំទាវ **អ៊ឹម សាឿន** អតីតអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ស្ពឺ ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ស្ថិតនៅសង្កាត់សុព័រទេព ក្រុងច្បារមនខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២។

❋ឯកឧត្ដម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកថវិកាមួយចំនួនយកទៅប្រគល់ជូនគណៈកម្មការរៀបចំពិធីបុណ្យអុំទូក នៅសាលាខេត្តតាកែវ នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២។

-ចូលរួមសូត្រមន្តកឋិនទានវត្តយុចិការ៉ែន ព្រមទាំងនាំយកនូវត្រៃយ៍កឋិនទាន១ និងបច្ច័យមួយចំនួន នៅឃុំព្រៃយុថ្កា ខេត្តតាកែវ នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមពិធីបុណ្យសពលោក **ឌុក សារ៉ាន់** ប្អូនបង្កើតរបស់លោកជំទាវ **ឌុក ស៊ីនិត** ភរិយារបស់ឯកឧត្ដម **គិន ណែត** នៅគេហដ្ឋាននៃសព ស្ថិតក្នុងភូមិចំបក់ឯម ឃុំរមេញ ស្រុកកោះអណ្ដែត ខេត្តតាកែវ នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២។



❋នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្ដម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាព្រឹទ្ធសភា ឯកឧត្ដម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីអបអរខួបអនុស្សាវរីយ៍លើកទី៦៩ នៃទិវាបុណ្យឯករាជ្យជាតិ៩វិច្ឆិកា ដឹកនាំដោយឯកឧត្ដម **ខេង ស៊ុម** ប្រធានក្រុមប្រឹក្សាខេត្ត និងឯកឧត្ដម **អ៊ុំ រាត្រី** អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ នៅសាលាខេត្តបន្ទាយមានជ័យ។

❋នាថ្ងៃទី១៤ និងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្ដម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញសហការជាមួយនឹងក្រុមគ្រូពេទ្យស្ម័គ្រចិត្តបេសកកម្មមនុស្សធម៌នៃប្រទេសបារាំង របស់ឯកឧត្ដមកិត្តិសង្គហបណ្ឌិត **ទេព ខុន** អនុប្រធានទី២ព្រឹទ្ធសភា ចុះទៅព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅក្នុងវិទ្យាល័យស្វាយចេក ស្រុកស្វាយចេក



ខេត្តបន្ទាយមានជ័យ។



❈នាថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ឆាយ ឫណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះ-សំណាលជាមួយនឹងក្រុមប្រឹក្សាឃុំជីរោទ៍ទី១ និងឃុំជីរោទ៍ទី២ ដើម្បីជំរុញចលនាបងប្អូនប្រជាពលរដ្ឋឱ្យទៅពិនិត្យ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ព្រមទាំងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំទាំង២ អំពីក្រុមសមាជិកព្រឹទ្ធសភាភូមិភាគទី២ គ្រោងយកអំណោយចែកជូនប្រជាពលរដ្ឋចំនួន២០០គ្រួសារ ដែលទទួលរងគ្រោះដោយសារជំនន់ទឹកភ្លៀង និងខូចខាតផល-ដំណាំ នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❈នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **គឹម ឆា** លេខា-ធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមចែកអំណោយដល់ប្រជាជនជួបការលំបាក ចាស់ជរា ចំនួន៣៥០គ្រួសារ ក្នុងបរិវេណវិទ្យាល័យស្វាយរៀង ក្រោមអធិ-បតីភាពលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី-ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបញ្ចុះបឋមសិលាកសាងអគារសិក្សាមួយខ្នង មាន៤បន្ទប់ នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមជាមួយនឹងក្រុមប្រឹក្សាស្រុកស្វាយជ្រំ និងសហការី ព្រមទាំងចុះជួបប្រជាពលរដ្ឋ និងក្រុមការងារចុះឈ្មោះបោះ-ឆ្នោត នៅឃុំឈើទាល ឃុំគ្រួស និងឃុំចំបក់ ដើម្បីឈ្វេងយល់នូវវឌ្ឍនភាពនៃការងារពិនិត្យឈ្មោះ និងការងារចុះឈ្មោះបោះ-ឆ្នោតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ស្ថិតស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២។

❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិធីសូត្រមន្តអង្គកឋិនទាន ដើម្បីដង្ហែទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស ក្នុងពុទ្ធសីមា នៅវត្តឧត្តមារាម (ថ្មី) ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយ-មានជ័យ នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២។



-ចូលរួមពិធីសូត្រមន្តបុណ្យអង្គកឋិនសាមគ្គី ដើម្បីដង្ហែទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស ក្នុងពុទ្ធសីមា នៅវត្តសុវណ្ណបុព្វតាខ្លាកូនចាស់ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២។

❈លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមការងារចុះឈ្មោះបោះ-ឆ្នោត និងក្រុមការងារបញ្ចូលទិន្នន័យ Data Entries ក្នុងសង្កាត់ផ្សារដើមថ្កូវ ខណ្ឌទួលគោក រាជធានីភ្នំពេញនាព្រឹកថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមកិច្ចប្រជុំរៀបចំកំណត់បែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រុមចលនាស្ត្រី ដល់ប្រធាន អនុប្រធានក្រុមការងារចលនាស្ត្រី រាជធានីភ្នំពេញ នាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមសំណេះសំណាលជាមួយនឹងក្រុមយុវជនភូមិសង្កាត់ផ្សារដើមថ្កូវ នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានី-ភ្នំពេញ នាព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមសំណេះសំណាលជាមួយនឹងក្រុមយុវជន និងក្រុមការងារ នៅសាលាខណ្ឌបឹងកេងកង រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២។

❈នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ឯកឧត្ដម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញទៅចុះឈ្មោះបោះឆ្នោត និងឈ្វេងយល់ពីការងារពិនិត្យចុះឈ្មោះបោះឆ្នោត នៅឃុំព្រៃទឹង ស្រុកស៊ីធរកណ្ដាល និងឃុំពានរោង ព្រមទាំងនាំយកបច្ច័យសម្រាប់សាងសង់សាលាឆាន់នៅវត្តព្រៃជ្រាំង និងចូលរួមបុណ្យកឋិនទាន នៅឃុំពានរោង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។

❈ឯកឧត្ដម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាគណៈអធិបតីភាពក្នុងពិធីប្រណាំងទូកខ្នាតអន្តរជាតិ នៅភូមិព្រៃអង្គរក្នុង ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំអំពិលតាពកស្មៀនឃុំ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំអំពិលតាពក ដើម្បីឈ្វេងយល់ការផ្ដល់សេវាសាធារណៈរបស់រដ្ឋបាលឃុំ ការងារអភិវឌ្ឍភូមិ ឃុំ ការងារសន្តិសុខ សណ្ដាប់ធ្នាប់ ការងារពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅសាលាឃុំអំពិលតាពក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខភរិយាឯកឧត្ដម **ឯម ដេត** សមាជិកក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ ដែលកំពុងសម្រាកព្យាបាលនៅគេហដ្ឋាន និងឧបត្ថម្ភថវិកាមួយចំនួន ស្ថិតក្នុងភូមិ៣ ឃុំអំពិលតាពក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២។

❈នារសៀលថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្ដម **ច្រឹង គីមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្ដម **ឌឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៩ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតកងយោធពលខេមរភូមិន្ទ ព្រមទាំងពិធីសម្ពោធវិមានឯករាជ្យ ក្រោមអធិបតីភាពឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្ដារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងអភិវឌ្ឍជនបទ នៅវិមានឯករាជ្យ ខេត្តកំពង់ចាម ។

❈នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២២ ឯកឧត្ដម **ឌឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះ-



សំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់ពីការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ និងពិនិត្យលើដំណើរការចុះឈ្មោះបោះឆ្នោត ព្រមទាំងដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដែលមេភូមិទាំង១០បានលើកឡើង និងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❈នាថ្ងៃទី១០ និងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្ដម **ញ៉ែប សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបូជាសពលោក **ជេត សុផល** សមាជិកក្រុមប្រឹក្សាស្រុកកណ្ដៀង នៅគេហដ្ឋានសព ស្ថិតក្នុងភូមិពោធិ៍កំបោរ ឃុំវាល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។

❈ឯកឧត្ដម **ច្រឹង គីមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីដង្ហែ និងបញ្ចុះសពឧបាសិកា **តិន គា** ភរិយាប្រធានក្រុមប្រឹក្សាស្រុកកោះសូទិន នៅក្នុងបរិវេណវត្តជីហែ ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន នៅខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។

-សហការជាមួយនឹងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត សម្ដេចឧត្ដមទេពញាណ **ហ៊ុន ណេង** ចុះទៅពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃចំនួន៣១៤នាក់ នៅឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២។

❈ឯកឧត្ដម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខថ្នាក់ដឹកនាំសាសនិកឥស្លាម និងប្រជាពលរដ្ឋ នៅភូមិព្រៃធំភ្នំព្រួស សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២។

-ជូនដំណើរលោកគ្រូ អ្នកគ្រូខ្មែរឥស្លាម និងបងប្អូនឥស្លាមចំនួន៩៨នាក់ ដែលបានចេញដំណើរទៅចូលរួមធ្វើធម្មយាត្រា នៅប្រទេសអារ៉ាប់ប៊ីសាអូឌីត នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នារសៀលថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិកំពង់កែសឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនថ្នាក់ដឹកនាំសាសនិកឥស្លាម និងប្រជាពលរដ្ឋ

សម្រាប់កសាងសាលារៀន នៅភូមិស្រែ សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត នារសៀលថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមរំលែកមរណទុក្ខ និងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប នារសៀលថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមរំលែកមរណទុក្ខ និងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិស្រែ សង្កាត់ត្រើយកោះ និងភូមិត្រពាំងធំ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី៥ និងថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយករង្វាន់ជូនសិស្សានុសិស្ស ដែលបានទទួលជ័យលាភីប្រចាំឆ្នាំ នៅភូមិអន្លង់ម៉ាក់ប្រាង្គ ឃុំស្នឹងកែវ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅក្នុងភូមិព្រៃខ្នង ឃុំព្រៃខ្នង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២។

❈នាថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **មួង ម៉ីយ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖



-រៀបចំពិធីបុណ្យកឋិនទាន ដើម្បីដង្ហែទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សា ក្នុងវត្តនាគវ័នគិរីរតនារាម នៅឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២។



-ជាគណៈអធិបតីក្នុងពិធីប្រណាំងទូក "ង" នៅស្រុកវើនសៃ ខេត្តរតនគិរី នាថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២២។

❈លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាល និងចែកពូជស្រូវជូនដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយជំនន់ទឹកភ្លៀងសរុបចំនួន៦.៨៤៤គ្រួសារ ក្នុងខេត្តកំពង់ធំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២។




-ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធសរុបចំនួន១.៥០០នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២។



-ចូលរួមដង្ហែអង្គកឋិនសាមគ្គីរបស់រដ្ឋបាលខេត្តកំពង់ធំ និងពុទ្ធបរិស័ទទៅកាន់វត្តឥន្ទ្រីយ៍សំវរៈ (ហៅវត្តកំពង់ធំ) ស្ថិតនៅសង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងកីឡាករទូក-ង ចំនួន៦ទូក



សរុបចំនួន១២៦នាក់ និងឧបត្ថម្ភគ្រឿងឧបភោគ បរិភោគសម្រាប់ទូក-ងនីមួយៗទទួលបាន៖ អង្ករចំនួន៥០គីឡូក្រាម មីចំនួន២កេស ត្រីខចំនួន២យួរ ទឹកត្រីចំនួន១យួរ ទឹកស៊ីអ៊ីវចំនួន១យួរ ទឹកបរិសុទ្ធចំនួន១០យួរ អាវយឺត មួក ក្រមា និងថវិកាមួយចំនួន នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២។



-នាំយកសម្ភារ រួមមាន៖ ការ៉ូ៦តឹកចំនួន៤៣កេស ស៊ីម៉ង់ត៍ចំនួន១តោន និងថវិកាមួយចំនួនប្រគល់ជូនលោកនាយកសាលា-បឋមសិក្សាអូរសាលា ដើម្បីក្រាលបន្ទប់សាលារៀនទើបសាងសង់ថ្មី នៅសាលាបឋមសិក្សាអូរសាលា ភូមិអូរសាលា ឃុំកំពង់-ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចូលរួមជាកិត្តិយសក្នុងពិធីបិទ និងប្រគល់ពានរង្វាន់ជូនដល់កីឡាករប្រណាំងទូក-ង និងបណ្តែតប្រទីប បង្ហោះគោមនៅខេត្តកំពង់ធំ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ នៅដងស្ទឹងសែន ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចុះសួរសុខទុក្ខ សំណេះសំណាល និងនាំយកថវិការបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី



នៃព្រះរាជាណាចក្រកម្ពុជា ចែកជូនបងប្អូនប្រជាពលរដ្ឋដែលរងគ្រោះដោយសារជំនន់ទឹកភ្លៀងចំនួន៤ភូមិ សរុប៣២៩គ្រួសារ នៅបរិវេណវត្តក្តីដូង ភូមិក្តីដូង ឃុំក្តីដូង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២។

❈នាថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក គង់** សមា-ជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសម្ពោធអគារវិទ្យាល័យ ហ៊ុន សែន ភ្នំសំពៅ ចំនួន១ខ្នង មាន២ជាន់ចំនួន២បន្ទប់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡា-ហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ថិតនៅភូមិភ្នំសំពៅកើត ឃុំភ្នំសំពៅ ស្រុកបាណន់ខេត្តបាត់ដំបង។

❈នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ស្រី បេន** សមា-ជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញសំណេះសំណាលជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ។

❈ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីសំណេះសំណាល និងនាំយកអំណោយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចែកជូនប្រជា-ពលរដ្ឋក្រីក្រ ចំនួន៣០០គ្រួសារ ក្នុងឃុំទាំង៦ នៅស្រុកត្រពាំងប្រាសាទ ព្រមទាំងចែកស្រូវពូជដល់ប្រជាពលរដ្ឋចំនួន៧០គ្រួសារដែលរងគ្រោះខូចខាតដោយសារទឹកជំនន់កន្លងមក នៅសាលាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាព្រឹកថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុក អភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ដើម្បីស្តាប់របាយការណ៍ស្តីពី វឌ្ឍនភាពការងារ



ខែតុលា និងទិសដៅការងារបន្ត ឆ្នាំ២០២២ របស់រដ្ឋបាលឃុំ និងស្រុក នារសៀលថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២។



-រៀបចំពិធីសូត្រមន្តអង្គកឋិនទានសាមគ្គី ដើម្បីដង្ហែទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស ក្នុងពុទ្ធសីមា នៅវត្តកោះកែវវិជ័យព្រៃដង្ហើម ហៅវត្តព្រៃដង្ហើម ខេត្តសៀមរាប នាថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២២។



-ប្រគល់ផ្ទះមួយខ្នងទំហំ៤ម៉ែត្រ x ៦ម៉ែត្រ ជូនលោក **ខិន មាន** ជាគ្រួសារក្រីក្រ នៅក្នុងភូមិត្រាំចាន ឃុំព្រះប្រឡាយ និងនាំយកអំណោយចែកជូនគ្រួសារក្រីក្រចំនួន១០គ្រួសារ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ ប្រធានក្រុម ចំនួន៤គ្រួសារ រួមមាន៖ អង្ករ មី ទឹកត្រី ទឹកស៊ីអ៊ីវ ម្សៅស៊ុប កន្ទេល ខ្នើយ និងភួយ ព្រមទាំងជួបសំណេះសំណាលជាមួយនឹងប្រធានឃុំ ក្រុម-ប្រឹក្សាឃុំ និងក្រុមការងារការិយាល័យចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតរបស់ឃុំ និងបន្តទៅពិនិត្យការសាងសង់ផ្ទះមួយខ្នងទៀត ទំហំ៤ម៉ែត្រ x ៦ម៉ែត្រ ដែលបានសន្យាសាងសង់ជូនដល់លោកស្រី **ចាប សេងហ៊ាង** (មេម៉ាយ) កូន៤នាក់ ជាគ្រួសារក្រីក្រ និងឧបត្ថម្ភថវិកាមួយចំនួន ស្ថិតក្នុងភូមិសែនសុខ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២។



-ចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រី ដើម្បីវាយតម្លៃវឌ្ឍនភាពការងារខែតុលា និងទិស-ដៅការងារខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលប្រជុំសាលាខេត្តឧត្តរ-មានជ័យ នាថ្ងៃទី៥ ខែវិច្ឆកា ឆ្នាំ២០២២។



-នាំយកអំណោយ រួមមាន៖ អង្ករ ត្រីខ មី ទឹកបរិសុទ្ធ ទឹកស៊ីអ៊ីវ ទឹកត្រី និងប៊ីចេង ចែកជូនប្រជាពលរដ្ឋក្រីក្រចំនួន២០គ្រួសារ និងប្រជាការពារភូមិចំនួន១០គ្រួសារ ព្រមទាំងទៅពិនិត្យមើលស្រូវពង្រោះ ដែលស្រុកបានយកពូជទៅចែកដល់បងប្អូនប្រជា-ពលរដ្ឋ និងបន្តពិនិត្យការដ្ឋានសាងសង់ផ្លូវចាក់បេតុងមួយខ្សែ នៅជុំវិញផ្សាររបស់ស្រុកត្រពាំងប្រាសាទ ស្ថិតក្នុងភូមិក្រសាំង ឃុំត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០២២។

❋ឯកឧត្តម **អ៊ឹង លាងហ៊្វ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធ-សភាបានអញ្ជើញ៖



-ចូលរួមគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខដ៏សែនក្រៀមក្រំ ចំពោះក្រុមគ្រួសារសពលោក **សុខ សារឿន** នាយសង្កាត់រដ្ឋ-

បាលផលផលផលគិរី ខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង នៅគេហដ្ឋានសពភូមិឡទឹកត្រី សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាខេត្ត ស្រុក ឃុំសរុបចំនួន៤៩នាក់ ដើម្បីពិនិត្យលទ្ធផលការងារខែវិច្ឆិកា និងលើកទិសដៅការងារខែធ្នូ ឆ្នាំ២០២២ និងផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីផែនការរួម ឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ជំនួយការស្មៀន មេប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានភូមិ ដើម្បីឈ្វេងយល់ពីដំណើរការចុះឈ្មោះបោះឆ្នោត និងស្តាប់របាយការណ៍រួមក្នុងមូលដ្ឋានព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន សម្រាប់មូលនិធិសង្គហធម៌ឃុំនៅសាលាឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២។

❈ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ដង្ហែអង្គកឋិនទាន ដើម្បីវេរប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាក្នុងពុទ្ធសីមានៅវត្តឫស្សី ស្ថិតក្នុងភូមិរបងក្រាស់ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២។

-ចូលរួមរំលែកមរណទុក្ខ និងគោរពវិញ្ញាណក្ខន្ធសពលោក **ខិត ខឌ្ឍនា** អភិបាលរង នៃគណៈអភិបាលខេត្តកំពត នៅគេហដ្ឋានសពស្ថិតនៅភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត នាព្រឹកថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមដង្ហែអង្គកឋិនទានទៅវេរប្រគេនព្រះសង្ឃគង់ចាំព្រះវស្សានៅវត្តវិបស្សនាធុរៈកែប ស្ថិតនៅក្នុងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៩ នៃទិវាបុណ្យឯករាជ្យជាតិ (៩ វិច្ឆិកា ១៩៥៣-៩ វិច្ឆិកា ២០២២) នៅឧទ្យានសម្តេចតេជោ ហ៊ុន សែន វិមានឯករាជ្យ ខេត្តកែប នាព្រឹកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងលោកនាយក លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅវិទ្យាល័យសម្តេច ហ៊ុន សែន អង្គសុភី ស្ថិតក្នុងឃុំអង្គសុភី ស្រុកកំពង់ត្រាច ខេត្តកំពត។

❈នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **សាយ ម៉ូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញដង្ហែអង្គកឋិនទាន ដើម្បីវេរប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាក្នុងពុទ្ធសីមា នៅវត្តឫស្សី ស្ថិតក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

❈នារសៀលថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំស្រុកអង្គរធំ ដើម្បីស្តាប់លទ្ធផលការងារដែលសម្រេចបាន និងលើកទិសដៅការងារបន្ត នៅសាលប្រជុំស្រុកអង្គរធំ ខេត្តសៀមរាប។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យកឋិនទានសាមគ្គីនៅវត្តប្រាសាទចន្ទរង្សី (គោកចាន់) នៅឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប នារសៀលថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២។

-ចូលបច្ច័យមួយចំនួនក្នុងបុណ្យកឋិនទានសាមគ្គីវត្តស្ទឹងមានជ័យ ស្ថិតនៅរាជធានីភ្នំពេញ នារសៀលថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកឋិនទានសាមគ្គីនៅវត្តព្រះឥន្ទ្រកោសា នៅភូមិបឹងដូនប៉ា ស្រុកស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចុះសួរសុខទុក្ខលោកតា **ហាប់ ពាខ** ដែលពិការជើងទាំងសងខាង និងបានឧបត្ថម្ភថវិកាមួយចំនួន នៅភូមិតាប្រុក ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២៕

## ការទទួលពាក្យបណ្តឹង

❈នៅខែតុលា ឆ្នាំ២០២២ ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន៦ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៧ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន៧ករណី កំពុងពិនិត្យសិក្សាចំនួន៥ករណី (សល់ពីខែមុន ២ករណី) ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន១ករណី៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២ សមាជិក សមាជិកា ព្រឹទ្ធសភាចំនួន១១រូប បានអញ្ជើញចូលរួមក្នុងពិធីពិសាអាហារ សាមគ្គី មិត្តភាព ជូនគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាវៀតណាម នៅអគារវឌ្ឍនៈ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។



❈នារាត្រីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២ សមាជិក សមាជិកា ព្រឹទ្ធសភាចំនួន៧រូប បានអញ្ជើញចូលរួមក្នុងពិធីលៀងសាយ-ភោជន៍ក្នុងឱកាសដែលគណៈប្រតិភូជាតិ និងអន្តរជាតិ អញ្ជើញ ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃមហាសន្និបាត អន្តរសភាអាស៊ានលើកទី៤៣ នៅសណ្ឋាគារសុខា រាជធានី-ភ្នំពេញ។

❈នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ សមាជិក សមាជិកា ព្រឹទ្ធសភាចំនួន២១រូប បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធី បើកកីឡាជាតិលើកទី៣ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានជាតិមរតកតេជោ ស្ថិតក្នុងភូមិព្រែកតាវ័ន្ត សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។



❈នារាត្រីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ សមាជិក សមាជិកា ព្រឹទ្ធសភាចំនួន៨រូប បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធី លៀងសាយភោជន៍ជូនថ្នាក់ដឹកនាំបណ្ដាប្រទេសសមាជិកអាយប៉ា និងសមាជិកសភាសង្កេតការណ៍ ភ្ញៀវជាតិ និងអន្តរជាតិ ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ សុខា រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **ឈិត គីមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំ ត្រៀមរៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ និងត្រៀមរៀបចំ កិច្ចប្រជុំទល់មុខគ្នារវាងថ្នាក់ដឹកនាំសភាអាយប៉ា និងប្រមុខ ដឹកនាំអាស៊ាន ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា និងជាប្រធានគណៈ-កម្មការរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី ៤៣ នៅសាលបាយ័ន វិមានរដ្ឋសភា។



❈នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិ-យសក្នុងពិធីបិទសន្និបាតខួប៣០ឆ្នាំ នៃសកម្មភាពមីននៅកម្ពុជា “ផ្ដល់ដីសុវត្ថិភាព បង្កើតស្នាមញញឹម” ក្រោមអធិបតីភាពដ៏ ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រព កោះពេជ្រ ។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជាគណៈអធិបតីភាពបើកសិក្ខាសាលាស្តីពី បច្ចេកវិទ្យាទំនើបលើវិស័យចិញ្ចឹមសត្វ និងមហាសន្និបាតរបស់សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅទីស្តីការក្រសួងបរិស្ថាន នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២។



-ចូលរួមជាកិត្តិយសក្នុងវេទិកាជំរុញពាណិជ្ជកម្ម និងវិនិយោគកម្ពុជា វៀតណាម ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ នាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងពេលល្ងាច និងកម្មវិធីពានរង្វាន់ធុរៈកិច្ចអាស៊ាន នៅសណ្ឋាគារសូហ្វីតែល នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលជួបសម្តែងការគួរសមជាមួយឯកឧត្តមប្រធានាធិបតី



ហ្វីលីពីន និងពិភាក្សាការងារវិនិយោគសម្រាប់ប្រទេសកម្ពុជា-ហ្វីលីពីន នៅសណ្ឋាគារហៃយ៉ាត់ Hyatt រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចូលរួមកិច្ចប្រជុំកំពូលធុរៈកិច្ច និងវិនិយោគអាស៊ាន គឺជាព្រឹត្តិការណ៍ដ៏ធំប្រចាំតំបន់អាស៊ីអាគ្នេយ៍ ដែលមានការអញ្ជើញចូលរួមពីប្រធានាធិបតី នាយករដ្ឋមន្ត្រី ធុរៈជន ក៏ដូចជាអ្នកជំនាញមកពីប្រទេសអាស៊ាន និងដៃគូសន្ទនារបស់អាស៊ានក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតី-តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានអាស៊ាន នៅសណ្ឋាគារសូហ្វីតែល រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២។

❋នាថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈិត គឹមយាត** ប្រធានស្តីទីគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការរៀបចំ នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ដើម្បីតាមដានវឌ្ឍនភាពការងារ ដឹកនាំដោយឯកឧត្តម **ស្ងួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥រដ្ឋសភា នៅសាលប្រជុំបាយ័ន វិមានរដ្ឋសភា។

❋នារសៀលថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ឈិត គឹមយ៉ាត** ប្រធានស្តីទីគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ



ចូលរួមក្នុងសម័យប្រជុំពេញអង្គលើកទី១ នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ក្រោមមូលបទ "បោះជំហានជាមួយគ្នាដើម្បីចីរភាព បរិយាបន្ន និងភាពធន់របស់អាស៊ាន" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជាគណៈអធិបតីភាពក្នុងពិធីបើកសិក្ខាសាលាវាយតម្លៃហានិភ័យ នៃការកើតភាពមិនប្រក្រតីក្នុងវិស័យសុខាភិបាល នៅសណ្ឋាគារសូហ្វីតែល រាជធានីភ្នំពេញ។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យកឋិនទានសាមគ្គី នៅគេហដ្ឋាន ខណ្ឌទួលគោក រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកឋិនទានសាមគ្គី នៅស្រុកកំពង់ត្រាច ខេត្តកំពត នារសៀលថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកឋិនទានសាមគ្គី នៅក្រសួងពាណិជ្ជកម្ម រាជធានីភ្នំពេញ នារសៀលថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកឋិនទាន នៅអង្គភាពប្រឆាំងអំពើពុករលួយ នៅរាជធានីភ្នំពេញ នារសៀលថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកឋិនទានសាមគ្គី នៅវត្តយុថិការវ័ន្ត (វត្តព្រៃយុថ្កា) ក្នុងឃុំព្រៃយុថ្កា ស្រុកកោះអណ្តែត ខេត្តតាកែវ នារសៀលថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២។

❈នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមទទួលបន្ទុកសហប្រតិបត្តិការជាមួយនឹងសហភាពអន្តរសភាកម្ពុជា ដឹកនាំដោយឯកឧត្តម **កែប ជុតិមា** ប្រធានគណៈកម្មការទី៤រដ្ឋសភា ដើម្បីត្រៀមលក្ខណៈចូលរួមកិច្ចប្រជុំក្រុមទទួលបន្ទុកសហប្រតិបត្តិការជាមួយសហភាពអន្តរសភាលើកទី១០ នៅប្រទេសវៀតណាម នាពេលខាងមុខ នៅវិមានរដ្ឋសភា។

❈ឯកឧត្តម **ឈិត គឹមយាត** ប្រធានស្តីទីគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីលៀងសាយភោជន៍ក្នុងឱកាសខួបទី៩៩ឆ្នាំ នៃថ្ងៃប្រកាសសាធារណរដ្ឋតួកគី ដែលរៀបចំឡើងដោយស្ថានទូត នៃសាធារណរដ្ឋតួកគីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចូលរួមប្រជុំទល់មុខគ្នារវាងថ្នាក់ដឹកនាំសភាអាយប៉ា (AIPA) និងប្រមុខដឹកនាំអាស៊ាន (ASEAN-AIPA Interface Meeting) ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ខាម ឃឿន** អនុប្រធានទី១រដ្ឋសភា និងជាប្រធានប្រតិភូ នៃគណៈប្រតិភូសភាកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងពិធីពិព័រណ៍ Walking through a songline ដែលរៀបចំឡើងដោយស្ថានទូតអូស្ត្រាលីប្រចាំនៅ




ព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម Hon Anthony Albanese នាយករដ្ឋមន្ត្រី នៃប្រទេសអូស្ត្រាលី នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខ និងសំណេះសំណាលលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា នៅគេហដ្ឋានលោកជំទាវ រាជធានីភ្នំពេញ នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២។



❈នាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំពិភាក្សាជាមួយនឹងសភារុស្ស៊ី ដើម្បីពិនិត្យលើសេចក្តីព្រាងបទអន្តរាគមន៍ និងបញ្ហាផ្សេងៗ សម្រាប់ត្រៀមរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ក្រោមអធិបតីភាពឯកឧត្តម **យឹម លាភ** សមាជិកគណៈកម្មការទី២រដ្ឋសភា និងជាប្រធានប្រតិភូដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយនឹងសភារុស្ស៊ី នៅសាលប្រជុំគណៈកម្មការទី២រដ្ឋសភា។

❈ឯកឧត្តម **ឆាយ ខណ្ណា** លេខាធិការគណៈកម្មការទី៥ ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយនឹងឯកឧត្តម Mohamad SALHAJRI ឯកអគ្គរាជទូតកូវ៉ែតដែលទើបនឹងតែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតកូវ៉ែតប្រចាំព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងកម្មវិធីរាត្រីសមោសរជួបជុំម្ចាស់អាជីវកម្មកម្ពុជា CEO Award 2022 “សម្រាប់សមាជិកគ្រួសារ CEO Master Club និងម្ចាស់អាជីវកម្មនៅកម្ពុជា ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯកបណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅសណ្ឋាគារសុខាភ្នំពេញ នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២។



❈នាថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ លោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំសមាជិកសភាស្ត្រីវ៉ាយប៉ាលើកទី៤៣ (WAIPA-43) សម្រាប់ត្រៀមរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (AIPA-43) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២រដ្ឋសភា និងជាប្រធានសមាជិកសភាស្ត្រីវ៉ាយប៉ា (WAIPA-43) នៅសាលប្រជុំបន្ទាយស្រី វិមានរដ្ឋសភា ។

❈នារសៀលថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យគម្រប់៧ថ្ងៃឧបាសិកា **លីវ យីន** ម្ដាយក្មេករបស់ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦

ព្រឹទ្ធសភា នៅផ្លូវលូ៥ ភូមិទ្រា៤ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

❈ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ ព្រឹទ្ធសភាបានអញ្ជើញៈ

-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារវិទ្យាល័យសម្តេចតេជោ **ហ៊ុន សែន** ភ្នំសំពៅ ១ខ្នង២ជាន់ មាន១២បន្ទប់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅភូមិភ្នំសំពៅកើត ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង នាថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយទិន្នន័យ និងផែនទីនៃការប្រើប្រាស់ដីធ្លីឆ្នាំ២០២២" ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅទីស្តីការក្រសួងបរិស្ថាន នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២។

❈លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ ព្រឹទ្ធសភាបានអញ្ជើញៈ



-ចូលរួមកិច្ចប្រជុំពិភាក្សារបស់គណៈកម្មាធិការសេដ្ឋកិច្ច នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ និងបញ្ហាផ្សេងៗ ក្រោមអធិបតីភាពឯកឧត្តម **ទី សុគន្ធ** លេខាធិការគណៈកម្មការទី៥រដ្ឋសភា និងជាប្រធានប្រតិភូសភាកម្ពុជា នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅសាលប្រជុំបន្ទាយស្រី វិមានរដ្ឋសភា នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការសេដ្ឋកិច្ច នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (AIPA-43) ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីព្រាង សេចក្តីសម្រេចចំនួន៣ ក្រោមអធិបតីភាពឯកឧត្តម **ឈាង វុន** ប្រធានគណៈកម្មការទី២ រដ្ឋសភា និងជាប្រធានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការសេដ្ឋកិច្ច នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅសាលប្រជុំបាយ័ន រដ្ឋសភា នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយនឹងសភាកូរ៉េខាងត្បូង ដើម្បីពិនិត្យឯកសារ បទអន្តរាគមន៍ និងបញ្ហាផ្សេងៗ សម្រាប់ត្រៀមរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (AIPA-43) ក្រោមអធិបតីភាព ឯកឧត្តម **ខៀវ តារិទ្ធ** លេខាធិការគណៈកម្មការទី៧រដ្ឋសភា និងជាប្រធានប្រតិភូដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយនឹងសភាកូរ៉េខាងត្បូង នៅសាលប្រជុំបន្ទាយស្រី រដ្ឋសភា នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២។



-ចូលរួមកិច្ចប្រជុំដើម្បីបញ្ចូលខ្លឹមសាររបស់ប្រទេសវៀណាម និងប្រទេសឥណ្ឌូណេស៊ី ដាក់ក្នុងសេចក្តីព្រាងសេចក្តីសម្រេចរបស់គណៈកម្មាធិការសេដ្ឋកិច្ច នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ក្រោមអធិបតីភាពឯកឧត្តម **ទី សុគន្ធ** លេខាធិការគណៈកម្មការទី៥រដ្ឋសភា និងជាប្រធានប្រតិភូសភាកម្ពុជា នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅសាលប្រជុំបន្ទាយស្រី រដ្ឋសភា នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២។

❈នាព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមសាកល្បងពិធីបើកកិច្ចប្រជុំគណៈកម្មការនានា នៃមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងកំណត់ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២២




*ឯកឧត្តម អ៊ុំ សារិទ្ធ និងឯកឧត្តម ឡោក ឆាយ ជាគណៈអធិបតី*

នាព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងលើកទិសដៅការងារសម្រាប់ខែវិច្ឆិកា ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

បន្ទាប់ពីការបញ្ចាំងវីដេអូបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២២ និងកិច្ចពិភាក្សាផ្លាស់ប្ដូរបទពិសោធន៍ការងារ បញ្ហាប្រឈម សំណូមពររួចមក ឯកឧត្តម **អ៊ុំ សារិទ្ធ** បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែតុលាថា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបំពេញភារកិច្ចផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារស្នូលទាំង៣ បានល្អគាប់ប្រសើរ ដោយបានរៀបចំចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងការបន្តសម័យប្រជុំលើកទី៩ ព្រឹទ្ធសភានីតិកាលទី៤ និងបានជួបសវនាការការងារជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងការចុះបំពេញមុខងារតំណាងតាមបណ្ដាខេត្ត ក្រុងនានាបានល្អ និងទាន់ពេលវេលា។

ចំពោះការងារសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំបែបបទ ផ្ដល់សេវា និងអមដំណើរសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងជំនួបសវនាការជាមួយនឹងថ្នាក់ដឹកនាំប្រទេសជាមិត្ត ព្រមទាំងកិច្ចប្រជុំអន្តរជាតិនានាបានយ៉ាងរលូន។

សម្រាប់ខែវិច្ឆិកាខាងមុខ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានណែនាំដល់គ្រប់អង្គភាពចំណុះទាំងអស់ ត្រូវបន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពក្នុងការផ្ដល់សេវាឱ្យកាន់តែល្អប្រសើរ និងទាន់ពេលវេលា ជូនដល់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទាំងអស់ ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល បានដាក់ចេញ ជាពិសេសវិធានការ “៣ការពារ ៣កុំ” និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារកុំឱ្យជំងឺកូវីដ-១៩ អាចឆ្លងរាលដាលជាថ្មីទៀតបាន៕

(អត្ថបទ៖ ធុន គីមជី រូបភាព៖ គឹម សិទ្ធី)



*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា*

# ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញធ្វើបាឋកថាស្តីពី តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភាកម្ពុជា ជូនសិស្សមន្រ្តីជាន់ខ្ពស់ និងកម្មសិក្សាការី នៃសាលាភូមិន្ទរដ្ឋបាល



*ឯកឧត្តម អ៊ុំ សារឹទ្ធ (ឆ្វេង) អធិបតីភាពក្នុងពិធីធ្វើបាឋកថា*

នាព្រឹកថ្ងៃអង្គារ ទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញធ្វើបាឋកថាស្តីពី តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជូនសិស្សមន្ត្រីជាន់ខ្ពស់ និងកម្មសិក្សាការី នៃសាលាភូមិន្ទរដ្ឋបាល នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមដោយផ្ទាល់ចំនួន១៤២នាក់ និងចូលរួមពីចម្ងាយតាមប្រព័ន្ធនិម្មិតចំនួន៤៧៩នាក់ ដែលសរុបមានចំនួន៦២១នាក់។

ក្នុងឱកាសនោះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានជម្រាបអំពី សាវតារ និងគោលបំណង នៃការបង្កើតព្រឹទ្ធសភា ព្រមទាំងដំណើរការ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា។

ព្រឹទ្ធសភា នីតិកាលទី១ កើតឡើងដោយសារការតែងតាំង ចាប់ពីនីតិកាលទី២ទៅទើបព្រឹទ្ធសភាកើតឡើងដោយសារការបោះឆ្នោតជាអសកលមិនចំពោះ មានសមាជិកព្រឹទ្ធសភាចំនួន៦១រូប មានអាណត្តិ៦ឆ្នាំ។

ចំណែកឯព្រឹទ្ធសភា នីតិកាលទី៤វិញ មានសមាជិកចំនួន៦២រូប ក្នុងនោះ២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ២រូបត្រូវបានជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដោយប្រៀប និងសមាជិកព្រឹទ្ធសភា៥៨រូបទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាអសកលមិនចំពោះ។ អង្គបោះឆ្នោត គឺតំណាងរាស្ត្រ និងក្រុមប្រឹក្សាឃុំសង្កាត់ទូទាំងប្រទេសក្នុងតំណែង។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់ថា ព្រឹទ្ធសភាមានមុខងារស្នូលចំនួន៣ គឺ៖មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង។ ក្រៅពីនេះ ព្រឹទ្ធសភានៅមានមុខងារគាំទ្រចំនួន២ទៀត គឺមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន។ ជាមួយគ្នានេះ ព្រឹទ្ធសភាមានអគ្គលេខាធិការដ្ឋាន ដែលជាសេនាធិការផ្ទាល់ឱ្យព្រឹទ្ធសភារ៉ាប់រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ សន្តិសុខ និងសេវាទាំងឡាយ ព្រមទាំងទំនាក់ទំនងទាំងក្នុង និងក្រៅស្ថាប័ន។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់បន្ថែមថា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាដឹកនាំដោយអគ្គលេខាធិការចំនួន១រូប និងអគ្គលេខាធិការរងជាជំនួយការ និងមានអង្គភាពចំណុះដូចជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ អគ្គនាយកដ្ឋានស្រាវជ្រាវ អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ និងអគ្គាធិការដ្ឋាន។

បន្ទាប់ពីស្តាប់ការធ្វើបាឋកថារួចមក សិស្សមន្ត្រីជាន់ខ្ពស់ និងកម្មសិក្សាការី នៃសាលាភូមិន្ទរដ្ឋបាល ក៏បានអញ្ជើញទស្សនាកន្លែងធ្វើការសំខាន់ៗរបស់ព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានា នៅក្នុងបរិវេណព្រឹទ្ធសភា៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ ធុន គីមជី )


*សិស្សមន្ត្រីជាន់ខ្ពស់ និងកម្មសិក្សាការីសាលាភូមិន្ទរដ្ឋបាល អញ្ជើញចូលរួមស្តាប់បាឋកថា*

# សិក្ខាសាលាស្ដីពី “សហគមន៍ជោគវាសនារួមកម្ពុជាចិន ប្រកៀកស្មាគ្នាឆ្ពោះទៅមុខក្នុងដំណើរថ្មី” ប្រព្រឹត្តទៅនៅព្រឹទ្ធសភាកម្ពុជា






*ឯកឧត្តម អ៊ុំ សារិទ្ធ (កណ្ដាល) អធិបតីភាពក្នុងអង្គសិក្ខាសាលា និងការប្រគល់ទទួលជំនួយមូលនីធិចិន ដើម្បីសន្តិភាព និងការអភិវឌ្ឍប្រចាំកម្ពុជា*

នារសៀលថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិមានព្រឹទ្ធសភា មានរៀបចំសិក្ខាសាលាស្ដីពី “សហគមន៍ជោគវាសនារួមកម្ពុជាចិន ប្រកៀកស្មាគ្នាឆ្ពោះទៅមុខក្នុងដំណើរថ្មី” ដែលបានប្រព្រឹត្តទៅក្នុងទម្រង់ចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ។

ពិធីបើកអង្គសិក្ខាសាលាប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា និងលោក **ឈួយ ឈុនឡាយ** ប្រធានការិយាល័យមូលនិធិចិន ដើម្បីសន្តិភាព និងការអភិវឌ្ឍប្រចាំកម្ពុជា ក្រោមកិច្ចសហការរៀបចំដោយវិទ្យុមិត្តភាពកម្ពុជា-ចិន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន ដោយមានការនិមន្ត និងអញ្ជើញចូលរួមពីព្រះសង្ឃ មន្ត្រីរាជការ និស្សិត និងអ្នកជំនាញជាច្រើន មកពីខុទ្ទកាល័យនាយករដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិប្រមាណជាង៨០នាក់។

ក្នុងឱកាសបើកអង្គសិក្ខាសាលា បានបញ្ចាំងលិខិតអបអរសាទររបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** ជូនអង្គសិក្ខាសាលា និងការថ្លែងរបស់លោក **អាន ស៊ីយូ** (An Xiaoyu) ប្រធានមជ្ឈមណ្ឌលកម្មវិធីភាសាចិន តំបន់អាស៊ី និងអាហ្វ្រិក នៃអគ្គស្ថានីយវិទ្យុ និងទូរទស្សន៍មជ្ឈិមចិន។

លោក **ឈួយ ឈុនឡាយ** ប្រធានការិយាល័យមូលនិធិចិន ដើម្បីសន្តិភាព និងការអភិវឌ្ឍប្រចាំកម្ពុជា បានមានប្រសាសន៍ថា សិក្ខាសាលានេះ គឺជាវេទិកាដ៏សំខាន់មួយ ដែលរៀបចំឡើងក្នុងគ្រាដ៏សំខាន់មួយនៅពេលដែលបក្ស-





*ទិដ្ឋភាពអ្នកចូលរួមក្នុងអង្គសិក្ខាសាលា*




*ទិដ្ឋភាពអ្នកអញ្ជើញចូលរួមក្នុងអង្គសិក្ខាសាលា*

កុម្មុយនិស្តចិនដឹកនាំប្រជាជនគ្រប់ក្រុមជនជាតិក្នុងប្រទេសចិន ដើម្បីចាប់ផ្តើមដំណើរថ្មី នៃទំនើបកម្មក្នុងការកសាងប្រទេសសង្គមនិយមតាមបែបផែនចិន និងឆ្ពោះទៅរកគោលដៅតស៊ូសតវត្សរ៍ទី២។

លោក **ឈួយ ឈុនឡាយ** ជឿជាក់យ៉ាងមុតមាំថា ការផ្លាស់ប្តូរដែលមិនធ្លាប់មានពីមុនមកក្នុងមួយសតវត្សរ៍កន្លងទៅ តាមរយៈស្ថានការណ៍អន្តរជាតិដ៏ស្មុគស្មាញ និងប្រែប្រួល ប៉ុន្តែតាមរយៈការខិតខំប្រឹងប្រែងរួមគ្នារបស់ប្រជាជនចិន និងកម្ពុជា សហគមន៍នៃជោគវាសនារួមនឹងប្រាកដឈានដល់កម្រិតថ្មីមួយ។ ទំនាក់ទំនងមិត្តភាពចិនកម្ពុជានឹងបន្តបង្កើនឱ្យកាន់តែប្រសើរឡើងនៅក្នុងយុគសម័យថ្មី ដូចប្រធានបទ នៃសិក្ខាសាលាថ្ងៃនេះ "សហគមន៍ជោគវាសនាកម្ពុជា-ចិន ប្រកៀកស្មាគ្នាឆ្ពោះទៅមុខក្នុងដំណើរថ្មី"។

មានប្រសាសន៍បើកអង្គសិក្ខាសាលា ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់ថា កម្មវិធីថ្ងៃនេះនឹងធ្វើឱ្យអ្នកចូលរួមបានយល់កាន់តែស៊ីជម្រៅពីសមាជលើកទី២០ របស់បក្សកុម្មុយនិស្តចិន ហើយក៏បានចូលរួមឆ្លុះបញ្ចាំងពីភាពរឹងមាំ នៃចំណងមិត្តភាពអមតៈរវាងកម្ពុជា-ចិន ដែលកំពុងវិវឌ្ឍជាសកល និងជាសកម្មភាពជំរុញចំណងមេត្រីភាពជាប្រពៃណីរវាងប្រទេសទាំងពីរ ដើម្បីបង្កើនល្បឿនចូលរួមជាមួយគ្នាក្នុងការកសាងសហគមន៍ជោគវាសនារួម ដោយចាប់ដៃគ្នាកសាងនូវភាពសុខុដុមរមនា សន្តិសុខគ្រប់ទីកន្លែង ការបើកទូលាយ យោគយល់គ្នា និងស៊ីជម្រៅនូវទំនាក់ទំនងរវាងប្រទេសទាំងពីរដែលបានប្រសិទ្ធនាមថា "ចំណងមិត្តភាពដែកថែប" ជាពិសេសរវាងសភា នៃប្រទេសទាំងពីរបង្កើតបានទំនាក់ទំនងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្រ្តគ្រប់ជ្រុងជ្រោយធានាដល់ដំណើរការ នៃការកសាងយុទ្ធសាស្រ្តខ្សែក្រវាត់ និងផ្លូវប្រព្រឹត្តទៅដោយរលូន ការពាររក្សាសន្តិសុខ ស្ថិរភាព និងអត្ថប្រយោជន៍ នៃការអភិវឌ្ឍក្នុងការកសាងសហគមន៍ជោគវាសនារួម ដែលមានលក្ខណៈយុទ្ធសាស្រ្ត។ ភាគីទាំងពីរបានក្លាយជាសហគមន៍ជោគវាសនាតែមួយ ដែលមានភាពជឿជាក់ និងទុកចិត្តគ្នាបានយ៉ាងពិតប្រាកដ និងយូរអង្វែង។

ជាមួយគ្នានោះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះមហាមិត្តចិនដែលជានិច្ចកាលតែងតែផ្តល់ការគាំទ្រចំពោះកម្ពុជាគ្រប់កាលៈទេសៈ ជាពិសេសបានឧបត្ថម្ភគាំទ្រជាបន្តបន្ទាប់ដល់ព្រឹទ្ធសភាកម្ពុជា ទោះបីជាអ័ព្ទនៃជំងឺកូវីដ-១៩មិនទាន់រលុបបាត់យ៉ាងណាក៏ដោយ។

ក្នុងឱកាសនោះដែរ ក៏មានការប្រគល់-ទទួលនិមិត្តរូបនូវសម្ភារអេឡិចត្រូនិកដែលជាជំនួយរបស់មូលនិធិចិនដើម្បីសន្តិភាព និងការអភិវឌ្ឍ ជូនដល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាផងដែរ៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ អ៊ុក ប៉ូលីន)

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២៨ ខែតុលា និងថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារីទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាជាមួយនឹងឯកឧត្តម **លី រស្មី** រដ្ឋលេខាធិការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យលើគម្រោងប្លង់រចនាផ្នែកខាងក្នុង នៃសាលនានាក្នុងអគារក្រហម និងប្លង់សាលប្រជុំព្រឹទ្ធសភាថ្មី នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារីទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិនិត្យពិភាក្សាការងាររបស់អង្គភាពលទ្ធកម្មនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅលើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្ម ឆ្នាំ២០២២ របាយការណ៍អនុវត្តកិច្ចលទ្ធកម្មរយៈពេល១០ឆ្នាំ និងការអនុម័តលើសេចក្តីព្រាងផែនការលទ្ធកម្មឆ្នាំ២០២៣ នៅសាលប្រជុំពិសេសខាងក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារីទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្របង្កើតសូចនាករគន្លឹះវាស់វែងលទ្ធផលការងារ Key Performance Indicators (KPIs) នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃប្រទេសបារាំងរបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខន** អនុប្រធានទី២ព្រឹទ្ធសភា ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋក្រីក្រដោយឥតគិតថ្លៃ នៅក្នុងវត្តបទុមគង្គា ស្ថិតនៅសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **កែវ ចាន់ណា** អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយនឹងកញ្ញា Kong Siqi នាយិកាវិទ្យុមិត្តភាពកម្ពុជា-ចិនប្រចាំកម្ពុជា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សហការជាមួយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម បានរៀបចំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទម្រង់ថ្មី ជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលអស់សុពលភាពប្រើប្រាស់ដើមឆ្នាំ២០២៣ និងខូចលក្ខណៈបច្ចេកទេស ព្រមទាំងបាត់បង់ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា៕



